**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការធានារ៉ាប់រងហានិភ័យការងារចំពោះបុគ្គលដែលស្ថិតនៅក្រោម ការគ្រប់គ្រងនៃច្បាប់ការងារ

ស្រាវជ្រាវចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **កែវ ហង្សបញ្ញា**

កញ្ញា **សៅ ច័ន្ទណារ៉ា**

ណែនាំដោយ

សាស្ត្រាចារ្យ **ម៉ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ៖ នីតិសាស្ត្រ

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ**កែវ ហង្សបញ្ញា** និងនាងខ្ញុំ **សៅ ច័ន្ទណារ៉ា** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២៣ ក្នុងឆ្នាំសិក្សា២០២២-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសម្រេចនូវកម្រងសារណានេះឡើង៖

ជាដំបូងយើងខ្ញុំសូមថ្លែងនូវការគោរពដឹងគុណយ៉ាងក្រៃលែងជូនចំពោះឪពុកម្តាយរបស់យើងខ្ញុំ ដែលបានចិញ្ចឹមបីបាច់ ថែរក្សា ផ្គត់ផ្គង់ ទំនុកបម្រុង ជ្រោមជ្រែង ការសិក្សារបស់យើងខ្ញុំតាំងពីបឋមសិក្សារហូតដល់ឆ្នាំបញ្ចប់សាកលវិទ្យាល័យថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ដែលការខិតខំអ្នកមានគុណទាំងពីរបានជម្រុញទឹកចិត្តយើងខ្ញុំខិតខំសិក្សារហូតដល់ទទួលបានឱកាសសរសេរសារណានេះដោយជោគជ័យ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំដឹកនាំ បង្កើតកម្មវិធីសិក្សាឱ្យស្របទៅតាមការអភិវឌ្ឍន៍នៃសង្គមជាតិ ក៏ដូចជាខិតខំស្វែងរកដៃគូសហការដែលជាសាកលវិទ្យាល័យអន្តរជាតិ ដើម្បីផ្តល់ឱកាសដល់សិស្សនិស្សិតក្នុងការផ្លាស់ប្តូរការសិក្សារយៈពេលខ្លីនៅសាកលវិទ្យាបរទេសដែលជាដៃគូ និងស្វែងរកអាហារូបករណ៍ដល់និស្សិតឱ្យមានបានសិក្សាបរទេសតាមជំនាញរបស់ខ្លួន។

បន្ថែមពីនេះយើងខ្ញុំក៏មិនភ្លេចគុណរបស់សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលបង្ហាត់បង្រៀនយើងខ្ញុំប្រកបដោយគុណភាពតាំងពីថ្នាក់មូលដ្ឋានរហូតឆ្នាំទី៤ ដែលជាឆ្នាំចុងក្រោយនៃថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកគ្រូសាស្ត្រាចារ្យ **ប៊ូយ ធីតា** ជាសាស្ត្រាចារ្យណែនាំ ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការជួយណែនាំ ផ្តល់ជាមតិយោបល់ កែតម្រូវ និងយោគយល់ លើកទឹកចិត្តយើងខ្ញុំ ដោយកត្តាទាំងនេះបានជំរុញឱ្យកិច្ចការសារណារបស់ក្រុមយើងខ្ញុំបញ្ចប់ដោយជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំសូមជូនពរដល់លោកឪពុក អ្នកម្តាយ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ អ្នកគ្រូសាស្ត្រាចារ្យណែនាំ និងមិត្តនិស្សិតរួមជំនាន់ រួមទាំងមិត្តអ្នកអានទាំងអស់ឱ្យមានសុខភាពល្អ ជួបតែសេចក្តីសុខ និងសេចក្តីចម្រើននៅក្នុងជីវិតតរៀងទៅ៕

# អារម្ភកថា

បន្ទាប់ពីយើងខ្ញុំបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល៤ឆ្នាំកន្លងមកនេះ យើងខ្ញុំបានក្រេបយកចំណេះដឹងជាច្រើនដែលបានកំណត់ក្នុងកម្មវិធីសិក្សារួមមាននីតិឯកជន នីតិសាធារណៈ ក៏ដូចជាការសិក្សាអំពីនីតិអន្តរជាតិផងដែរ។ ក្រោមការខិតខំបង្ហាត់បង្រៀនកន្លងមករបស់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យបានផ្តល់ទាំងចំណេះដឹង ព្រមទាំងជួយជាយោបល់ដែលជាស្ពាននាំឱ្យយើងខ្ញុំមានឱកាសក្នុងការចងក្រងនូវការបញ្ចប់សារណានេះ។

យើងខ្ញុំបានសម្រេចជ្រើសរើសប្រធានបទក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ដែលទាក់ទងនឹងផ្នែកនីតិឯកជនដែលប្រធានបទនេះនិយាយអំពី «**ការធានារ៉ាប់រងចំពោះផ្នែកហានិភ័យការងារចំពោះបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ការងារ**»។ មូលហេតុដែលយើងខ្ញុំជ្រើសរើសប្រធានបទនេះមកសរសេរចងក្រងពីព្រោះផ្នែកហានិភ័យការងារនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះប្រជាពលរដ្ឋទូទៅក្នុងការយល់ដឹងអំពីសិទ្ធិរបស់ខ្លួន និងអត្ថប្រយោជន៍នានាក្នុងការទទួលបានការការពារធានារ៉ាប់រងនៅពេលមានគ្រោះថ្នាក់ណាមួយដែលចាត់ជាហានិភ័យការងារ។ បន្ថែមពីនេះ ការចងក្រងសារណាក៏មានគោលបំណងក្នុងការចែករំលែកនូវការគ្រប់គ្រងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារពោះបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ការងារនៅកម្ពុជា និងនីតិវិធីក្នុងការទទួលបាននូវធានារ៉ាប់រងផ្នែកហានិភ័យការងារ ថាដើម្បីទទួលបានការធានារ៉ាប់រងចំពោះផ្នែកហានិភ័យការងារ តើនិយោជក និងកម្មករនិយោជិតត្រូវបំពេញនិងឆ្លងកាត់នីតិវិធីអ្វីខ្លះ?

យើងខ្ញុំសង្ឃឹមថាសារណានេះនឹងផ្តល់ជាប្រយោជន៍ដល់អ្នកអានដែលមានបំណងចង់ឈ្វេងយល់ពីរបបសន្តិសុខសង្គម ជាពិសេសពោះផ្នែកហានិភ័យការងារចំពោះបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ការងារ។ យើងខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំថាសារណានេះក៏អាចក្លាយជាមូលដ្ឋាន និងជំនួយដល់សិស្សជំនាន់ក្រោយក្នុងការសិក្សាស្រាវជ្រាវនៅថ្ងៃអនាគត។

ជាចុងក្រោយយើងខ្ញុំសូមថ្លែងអរគុណចំពោះការអានសារណារបស់យើងខ្ញុំ ក៏ដូចជាសូមអភ័យទោសផងដែរ ប្រសិនបើការស្រាវជ្រាវរបស់យើងខ្ញុំមានការខ្វះខាតចំពោះពាក្យពេចន៍ ខ្លឹមសារ និងអត្ថន័យនានាដោយអចេតនាពីយើងខ្ញុំ យើងខ្ញុំស្វាមន៍នូវការរិះគន់នានា ដែលជួយកែលម្អសារណានេះឱ្យមានភាពកាន់តែល្អប្រសើរជាងមុន៕

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ**

**១.១. សញ្ញាណគតិយុត្តនៃរបបសន្តិសុខសង្គម** ........ ៦

**១.១.១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត** ........ ៦

១.១.១.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ........ ៦

១.១.១.២.ច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ ........ ៦

១.១.១.៣.ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារ ឆ្នាំ ២០០២ ........ ៧

១.១.១.៤. អនុក្រឹត្យលេខ ១៦ អនក្រ.បកស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម ........ ៩

១.១.១.៤.១. រដ្ឋបាលបេឡាជាតិរបបសន្តិសង្គម ........ ១១

១.១.១.៤.២. ការគ្រប់គ្រងហិរញ្ញវត្ថុ ........ ១៣

១.១.១.៤.៣. ភាគទាន និងតាវកាលិកសន្តិសុខសង្គម ........ ១៤

១.១.១.៦. ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩ ........ ១៤

**១.១.២. ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច** ........ ១៦

១.១.២.១. ក្រុមប្រឹក្សាជាតិគាំពារសង្គម ........ ១៦

១.១.២.២. និយ័តករសន្តិសុខសង្គម ........ ១៦

១.១.២.៣. បេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ........ ១៦

១.១.២.៣.១. ភារកិច្ចរបស់បេឡាជាតិសន្តិសុខសង្គម ........ ១៧

១.១.២.៣.២. ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម ........ ១៨

១.១.២.៣.៣. អង្គភាពប្រតិបត្តិនៃបេឡាជាតិសន្តិសុខសង្គម ........ ១៨

**១.២. សញ្ញាណនៃផ្នែកហានិភ័យការងារ** ........ ១៩

**១.២.១. និយមន័យ** ........ ១៩

**១.២.២. ប្រភេទនៃហានិភ័យការងារ** ........ ១៩

១.២.២.១. គ្រោះថ្នាក់ការងារ ........ ១៩

១.២.២.២. គ្រោះថ្នាក់ការងារក្នុងពេលធ្វើដំណើរ ........ ១៩

១.២.២.៣. ជម្ងឺវិជ្ជាជីវៈ ........ ១៩

# ជំពូកទី២
# នីតិវិធីក្នុងការទទួលបាននូវតាវកាលិកផ្នែកហានិភ័យការងារ

២.១. ការងារចុះបញ្ជិកាក្នុងប.ស.ស. .......... ២២
**២.១.១. ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន** .......... ២៣
២.១.១.១. រយៈពេលនៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន .......... ២៣
២.១.១.២. លក្ខខណ្ឌទម្រង់នៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន .......... ២៣
**២.១.២. ការចុះបញ្ជិកាកម្មករនិយោជិត** .......... ២៣
២.១.២.១. បែបបទក្នុងការចុះបញ្ជិកាកម្មករនិយោជិត .......... ២៣
២.១.២.២. ករណីខូច ឬបាត់បង់ប័ណ្ណសមាជិកប.ស.ស. .......... ២៥
២.១.២.៣. របាយការណ៍ចំនួនកម្មករនិយោជិតក្រោយពីការចុះបញ្ជិការួច .......... ២៥
**២.២. ការបង់ភាគទានផ្នែកហានិភ័យ** .......... ២៥
**២.២.១. កាតព្វកិច្ច និងអត្រា** .......... ២៥
**២.២.២. កាលបរិច្ឆេទ** .......... ២៦
**២.២.៣. របៀបបង់ភាគទានផ្នែកហានិភ័យការងារ** .......... ២៦
**២.៣. ដំណើរការនីតិវិធីក្នុងការទទួលបាននូវតាវកាលិកផ្នែកហានិភ័យការងារ** .......... ២៦
**២.៣.១. ការជូនដំណឹង និងការអង្កេតហានិភ័យការងារ** .......... ២៧
**២.៣.២. តាវកាលិកផ្នែកហានិភ័យការងារ** .......... ២៨
២.៣.២.១.សេវាថែទាំវេជ្ជសាស្ត្រ ព្យាបាល និងសង្គ្រោះបន្ទាន់ .......... ២៨
២.៣.២.២. តាវកាលិកបាត់បង់សមត្ថភាពការងារ .......... ២៩
២.៣.២.៣. ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព .......... ៣៤
២.៣.២.៤. តាវកាលិកឧត្តរជីវី .......... ៣៤
២.៣.២.៤. សេវាបុននីតិសម្បទា .......... ៣៦
២.៣.២.៥.  ជម្ងឺរ៉ាំរ៉ៃ .......... ៣៧
**សេចក្តីសន្និដ្ឋាន** .......... ៣៤
**អនុសាសន៍** .......... ៣៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

កម្ពុជាបានអនុវត្តន៍ផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសរបស់ខ្លួនពីប្រទេសដែលមានចំណូលកម្រិតទាបឈានទៅប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។[1] ដើម្បីសម្រេចនូវគោលនយោបាយនេះបានរាជរដ្ឋាភិបាលបានខិតខំអនុម័ត ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីទាក់ទាញវិនិយោគិនទាំងក្នុង និងក្រៅប្រទេស ក្នុងការមកវិនិយោគនៅកម្ពុជា។ នៅពេលដែលមានការវិនិយោគនៅកម្ពុជាទៅលើការបង្កើតសហគ្រាស គ្រឹះស្ថាន រោងចក្រ ក្រុមហ៊ុនច្រើន គឺជាកត្តាពន្លឿនសេដ្ឋកិច្ចមួយដែលនាំមកនូវឱកាសការងារជាច្រើនដល់ប្រជាជនកម្ពុជាដើម្បីធ្វើការផ្គត់ផ្គង់ជីវិតប្រចាំថ្ងៃ។ ភាពមានការងារធ្វើជម្រុញឱ្យមានការលូតលាស់នូវកំណើនសេដ្ឋកិច្ចជាតិឱ្យកាន់តែមានភាពរីកចម្រើន ដែលលទ្ធផលទាំងនេះបានបង្កើននូវប្រាក់ចំណូលជូនប្រជាជនកម្ពុជា ក៏ដូចជាជួយឡើងតម្កើនស្តង់ដាររស់នៅរបស់ប្រជាជន និងជួយកាត់បន្ថយភាពក្រីក្រផងក្នុងសង្គមដែរ។ តួយ៉ាងការងារនៅក្នុងវិស័យនីមួយៗសុទ្ធសឹងតែអាចបង្កនូវផលប៉ះពាល់ និងហានិភ័យផ្សេងៗដល់សុខាលមាលភាពរបស់កម្មករនិយោជិតនៅក្នុងពេលបំពេញសកម្មភាពការងារ។ ហេតុដូចនេះហើយ ទើបគោលនយោបាយរបស់រដ្ឋាភិបាលបានបង្កើតនូវរបបសន្តិសុខសង្គមដែលគ្រប់គ្រងដោយអង្គភាពបេឡាជាតិសន្តិសុខសង្គមសរសេរកាត់ **«ប.ស.ស.»** ដើម្បីធានាទៅលើការថែទាំសុខភាពរបស់ប្រជាពលរដ្ឋនៅពេលជួបប្រទះនូវហានិភ័យការងារនានា ដែលរាជរដ្ឋាភិបាលបានគិតគូរដល់ជីវភាពរបស់កម្មករនិយោជិតនៅពេលដែលខ្លួនបាត់បង់សមត្ថភាពប្រកបការងារនៅក្នុងរយៈពេលបណ្តោះអាសន្ន ឬក៏គ្រោះថ្នាក់ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ និងគ្រោះថ្នាក់រហូតដល់មរណភាព។

ការបង្កើតនូវរបបសន្តិសុខសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនមែនទើបតែមាននៅក្នុងសម័យបច្ចុប្បន្ននោះទេ គឺរបបនេះត្រូវបានបង្កើតឡើងចាប់តាំងពីតាំងពីឆ្នាំ១៩៥៥មកម្លេះ ដោយយោងតាមព្រះរាជក្រឹត្យលេខ៩៥ និង៣០៦។[2] តែគួរឱ្យសោកស្តាយណាស់ដែលរបបសន្តិសុខសង្គមនេះត្រូវបានលុបបំបាត់ចោលទាំងស្រុងនៅក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ដោយប្រជាពលរដ្ឋកម្ពុជានៅក្នុងសម័យកាលនោះមិនបានទទួលការគាំពារ ឬទទួលសេវាថែទាំ និងព្យាបាលសុខភាពពីរាជរដ្ឋាភិបាលនោះឡើយ។ យ៉ាងណាមិញ ក្រោយពីការផ្តួលរលំរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩មក កម្ពុជាបានឆ្លងកាត់នូវការផ្លាស់ប្តូររបបនយោបាយជាច្រើន

---

[1] ហាន់ ស.(២០២៣). *កម្ពុជានឹងសម្រេចបានជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ខាងមុខ.* ដកស្រង់ចេញពី https://www.information.gov.kh/articles/106424 ថ្ងៃទី០៥ មិថុនា ២០២៣។

[2] បេឡាជាតិសន្តិសុខសង្គម.(២០១៤) ប្រវត្តិសង្ខេប, ដកស្រង់ចេញពី https://www.nssf.gov.kh/%e1%9e%a2%e1%9f%86%e1%9e%96%e1%9e%b8%e2%80%8b-%e1%9e%94-%e1%9e%9f%e1%9e%9f/%e1%9e%94%e1%9f%92%e1%9e%9a%e1%9e%9c%e1%9e%8f%e1%9f%92%e1%9e%8f%e1%9e%b7%e1%9e%9a%e1%9e%bc%e1%9e%94/។

សម័យកាល ដែលក្នុងការកាន់អំណាចរបស់រាជរដ្ឋាភិបាលដឹកនាំប្រទេសនាសម័យនោះបានខិតខំស្តាររបបសន្តិសុខសង្គមឡើងវិញ ដូចជា នៅក្នុងចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ បានផ្តល់នូវសេវាថែទាំសុខភាពដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋ។ បន្ទាប់មក នៅក្នុងឆ្នាំ១៩៩៣ នាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើង តែត្រូវបានផ្លាស់ប្តូរឈ្មោះមកអគ្គនាយកដ្ឋានការងារវិញនាឆ្នាំ១៩៩៧ ដែលច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុម័ត ក្នុងគោលបំណងអនុវត្តកិច្ចគាំពារសន្តិសុខសង្គមដល់ប្រជាជនដែលធ្វើការក្នុងវិស័យឯកជន។ អង្គភាពប.ស.ស. បានចាប់ផ្តើមអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ស្តីពីការងារនៅឆ្នាំ២០០៨រហូតដល់បច្ចុប្បន្ននេះ។[3] ដូច្នោះ ចំណោទបញ្ហាដែលចោទសួរគឺ តើការធានារ៉ាប់រងហានិភ័យការងារចំពោះបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ការងារ ត្រូវបានប្រព្រឹត្តទៅយ៉ាងដូចម្តេចនៅក្នុងព្រះរាជាណាចក្រកម្ពុជា?

ជាការពិតណាស់ការធានារ៉ាប់រងហានិភ័យការងារពិតជាមានគុណប្រយោជន៍ ក៏ដូចជាធានាបានឱ្យមាននូវសមធម៌ សាមគ្គីភាពសង្គម និងលើកកម្ពស់សុខលមាលភាព រួមទាំងជីវភាពរបស់ប្រជាពលរដ្ឋដែលជាកម្មករនិយោជិតទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដែលធ្វើសកម្មភាពការងារនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។[4] លើសពីនេះទៅទៀត ការធានារ៉ាប់រងនេះបានលាតសន្ធឹងដល់សិទ្ធិវន្តរបស់សាមីជនផងដែរ នៅក្នុងករណីសមីជនទទួលមរណភាពនៅពេលរងគ្រោះថ្នាក់ការងារដែលចាត់ចូលជាផ្នែកមួយនៃហានិភ័យការងារ។ ជាទូទៅ បើទោះបីជាមានការគាំពារចំពោះកម្មករនិយោជិតនៅពេលមានហានិភ័យក៏ដោយ ក៏ការធានារ៉ាប់រងនោះអាចអនុវត្តបានលុះត្រាតែនិយោជិកដែលគ្រប់គ្រងកម្មករនិយោជិតបានធ្វើការចុះបញ្ជិកាសហគ្រាសគ្រឹះដ្ឋាន និងកម្មករនិយោជិតដំណាលគ្នាឱ្យបានត្រឹមត្រូវផ្អែកតាមនីតិវិធីដែលបានអនុលោមភាពតាមលិខិតបទដ្ឋានគតិយុទ្ធដែលចូលជាធរមានក្រោមដែនសមត្ថកិច្ចរបស់បេឡាជាតិរបបសន្តិសុខ។ គួរបញ្ជាក់ផងដែរថា ការចុះបញ្ជិកានៅ ប.ស.ស. របស់សហគ្រាសគ្រឹះស្ថាន និងកម្មករនិយោជិតតែមួយមិនអាចបំពេញនូវលក្ខខណ្ឌក្នុងការទទួលបានធានារ៉ាប់រងហានិភ័យការងារនោះទេ គឺនិយោជក ឬម្ចាស់សហគ្រាសត្រូវទាមទារឱ្យមានការឆ្លងកាត់នីតិវិធី និងបំពេញនូវកាតព្វកិច្ចមួយចំនួនទៀតបន្ទាប់ពីក្លាយជាសមាជិកប.ស.ស. រួមមាន ការបង់ភាគទានផ្នែកហានិភ័យទៅតាមអត្រា និងកាលបរិច្ឆេទដែលបានកំណត់ដោយច្បាប់ពាក់ព័ន្ធកាតព្វកិច្ចជូនដំណឹងព័ត៌មានមួយចំនួនដែល ប.ស.ស. តម្រូវ។ បន្ថែមពីនេះ នីតិវិធីបន្តបន្ទាប់ក៏រួមបញ្ចូលទាំងដំណើរការនីតិវិធីក្នុងការទទួលបាននូវតាវកាលិកផ្នែកហានិភ័យការងារ ដែលដំណើរការនេះគឺធ្វើឡើងបន្ទាប់ពី

[3] ប្រកាសលេខ ០២២/០៨ កប/ប្រក ចុះនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ។

[4] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩, មាត្រា១។

ហានិភ័យការងារត្រូវបានកើតឡើងចំពោះកម្មករនិយោជិត ហេតុដូចនេះបានដំណើរការនេះពិតជាមានសារសំខាន់ខ្លាំងណាស់ចំពោះបុគ្គលដែលជាកម្មករនិយោជិតផ្ទាល់ក្នុងការយល់ដឹងថាខ្លួនត្រូវធ្វើដូចម្តេចខ្លះ ដើម្បីទាមទារអត្ថប្រយោជន៍របស់ខ្លួន និងទទួលបានការធានារ៉ាប់រងហានិភ័យការងារពី ប.ស.ស.។

ដោយការសម្លឹងឃើញនូវភាពស្មុគស្មាញចំពោះការបែងចែកសញ្ញាណទូទៅនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងនីតិវិធីក្នុងការទទួលបាននូវធានារ៉ាប់រងផ្នែកហានិភ័យការងារ ទើបធ្វើឱ្យយើងខ្ញុំជ្រើសរើសយកប្រធានបទ «ការធានារ៉ាប់រងហានិភ័យការងារចំពោះបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ការងារ» នេះមកធ្វើការសិក្សាស្រាវជ្រាវ និង វែកញែកដើម្បីកំណត់ប្រភេទហានិភ័យការងារនីមួយៗឱ្យបានច្បាស់លាស់ និងចងក្រង រៀបរៀងនីតិវិធីការទទួលបាននូវធានារ៉ាប់រងផ្នែកហានិភ័យការងារឱ្យបានល្អ ងាយយល់ តាមលំដាប់លំដោយ។

ការស្រាវជ្រាវនេះនឹងផ្តល់គុណប្រយោជន៍ដល់និស្សិត ក៏ដូចជាសារធារណជនទូទៅ ឱ្យបានដឹងពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ និងនីតិវិធីក្នុងការទទួលបានការធានារ៉ាប់រងហានិភ័យការងារចំពោះបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ការងារ។ ទន្ទឹមនឹងនេះដែរ យើងខ្ញុំនឹងសិក្សាយ៉ាងលម្អិតទៅលើ ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ប្រភេទនៃហានិភ័យការងារ ក៏ដូចជានីតិវិធីនីមួយៗក្នុងការទទួលបាននូវធានារ៉ាប់រងផ្នែកហានិភ័យការងារ ដើម្បីឱ្យមិត្តនិស្សិតងាយស្រួលក្នុងការអាន និងក្រេបយកចំណេះដឹងមូលដ្ឋានអំពីការធានារ៉ាប់រងផ្នែកហានិភ័យការងារពីសារណាផងដែរ។

ដើម្បីសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំបានសិក្សាស្រាវជ្រាវយ៉ាងលម្អិតទៅលើច្បាប់ លិខិតបទដ្ឋានដែលពាក់ព័ន្ធ ក៏ដូចជាតាមរយៈសៀវភៅ ព័ត៌មាន និងទិន្នន័យនៅក្នុងគេហទំព័រផ្លូវការនានារបស់ក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ។

ក្នុងប្រធានបទនេះ យើងខ្ញុំបែងចែកជាពីរជំពូកធំៗ គឺជំពូកទី១ សិក្សាទាក់ទងនឹងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ យើងនឹងធ្វើការបកស្រាយលម្អិតទៅលើពីរផ្នែកធំៗរួមមាន៖ ជំពូកទី១ សិក្សាអំពីរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និង ផ្នែកទី២ សញ្ញាណនៃផ្នែកហានិភ័យការងារ។ ចំពោះជំពូកទី២ សិក្សាអំពីនីតិវិធីក្នុងការទទួលបាននូវធានារ៉ាប់រងផ្នែកហានិភ័យការងារ ដែលមានបីផ្នែកធំៗដូចជា ផ្នែកទី១ ការងារចុះបញ្ជិកាក្នុង ប.ស.ស. ផ្នែកទី២ ការបង់ភាគទានផ្នែកហានិភ័យការងារ និងផ្នែកទី៣ ដំណើរការនីតិក្នុងការទទួលបាននូវតាវកាលិកផ្នែកហានិភ័យការងារ។

# ជំពូកទី១

# របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

# ជំពូកទី១

# របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

យោងតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តដោយសភានៅក្នុងឆ្នាំ២០១៩ បានបញ្ញត្តអំពីយន្តការអនុវត្ត និងប្រព័ន្ធគ្រប់គ្រងរបបសន្តិសុខសង្គមដោយបែងចែកជាបួនប្រភេទ ក្នុងនោះមានផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ។[5] ជាទូទៅក្នុងចំណោមប្រភេទរបបសន្តិសុខសង្គមទាំងបួនផ្នែកនេះ ផ្នែកហានិភ័យការងារចាត់ចូលជាប្រធានបទដ៏សំខាន់ចំពោះកម្មករនិយោជិតនៅក្នុងស្ថាប័នសាធារណៈ និងវិស័យឯកជនប៉ុន្តែផ្នែកនេះបានដើរតួយ៉ាងសំខាន់នៅក្នុងការអនុវត្តនៅក្នុងវិស័យការងារជាពិសេសនៅក្នុងវិស័យឯកជន ដែលការពារបុគ្គលទាំងអស់ដែលស្ថិតក្រោមបញ្ញត្តិនៃច្បាប់ស្តីពីការងារ។ បើយោងតាមសេចក្តីជូនដំណឹងស្តីពីលទ្ធផលពិធីប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានប្រចាំឆ្នាំ២០២២ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៣ របស់ប.ស.ស. បានផ្តល់តាវកាលិកហានិភ័យការងារសម្រាប់វិស័យឯកជនសរុបចំនួន ១៣ ៧៤២ឯកសារ មានជនរងគ្រោះចំនួន ៩ ០១៣នាក់ ស្រីចំនួន ៤ ៥២១នាក់ ដែលមានអ្នកចូលប្រើប្រាស់សេវាមូលដ្ឋានសុខាភិបាលចំនួន ១៣ ៥០៦ករណី ស្រីចំនួន ៧ ១៦៦ករណី និងផ្តល់សេវាស្តារនីតិសម្បទាសរុបចំនួន ១៥៧ដង.នាក់ ស្រីចំនួន ៥៩ដង.នាក់ សរុបចំណាយអស់ ២២,៣០ប៊ីលានរៀល។ នៅក្នុងឆ្នាំ២០២៣ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារចំពោះវិស័យឯកជនទទួលបានការចុះបញ្ជី សហគ្រាស គ្រឹះស្ថាន ចំនួន ២២ ៩៣១ មានកម្មករនិយោជិតចំនួន ២ ២៩៩ ៨០២នាក់ ក៏ដូចជាការប្រមូលភាគទានពីនិយោជកសរុបបានចំនួនប្រមាណ ១០៧៤៣ាន់ ២៤៦លានរៀល (ស្មើនឹងប្រមាណ ២៦២លាន ១១ ពាន់ដុល្លារអាមេរិក) និងចំណាយសរុបប្រមាណ ១៧៤៣ាន់ ៨៧លានរៀល (ស្មើនឹងប្រមាណ ៤២លាន ៤៦០ ពាន់ដុល្លារអាមេរិក)។[6]

យោងតាមសេចក្តីជូនដំណឹងទាំងនេះ ចំនួននៃកម្មករនិយោជិតនៅក្នុងវិស័យឯកជនបានប្រើប្រាស់ការធានារ៉ាប់រងផ្នែកហានិភ័យការងារនេះមានចំនួនច្រើន ដែលការធានារ៉ាប់រងនេះបានចូលរួមចំណែកដោះស្រាយបន្ទុកបញ្ហាជីវភាពនៃកម្មករនិយោជិតផងដែរ។ ដើម្បីទ្រទ្រង់ស្ថាប័នប.ស.ស. ក្នុងការផ្តល់ជាតាវកាលិកជូនចំពោះជនរងគ្រោះតាមតម្រូវការ គឺធនធានផ្នែកហានិភ័យការងារកើតឡើងចេញពីប្រភពបីធំៗដូចជា ការបង់

[5] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩, មាត្រា២។

[6] សេចក្តីជូនដំណឹងលេខ ០៣៥/២៣ ប.ស.ស. ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារស្នាក់ការកណ្តាលបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ភាគទានពីរដ្ឋនិងនិយោជក ផលដែលបានមកពីការវិនិយោគ និងអំណោយឬអច្ច័យទាននិងប្រភពស្របច្បាប់ដទៃផ្សេងទៀត។[7]

ការអនុវត្ត និងការផ្តល់សេវាធានារ៉ាប់រងរបបសន្តិសុខផ្នែកហានិភ័យការងារជូនចំពោះកម្មករនិយោជិតដែលអនុលោមដោយច្បាប់ស្តីពីការងារ ក៏ដូចជាបុគ្គលផ្សេងទៀតដែលស្ថិតនៅក្នុងវិស័យសាធារណៈ និងបុគ្គលដែលត្រូវបានធានារ៉ាប់រងហានិភ័យការងារដែលបានចែងនៅក្នុងច្បាប់ដោយឡែកក៏ដោយ សុទ្ធសឹងតែអនុវត្តទៅបានលុះត្រាតែមានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងការគោលដៅរបស់ខ្លួន ដោយមានទាំងការបង្កើតស្ថាប័ន ប.ស.ស. និងការជ្រើសរើសមន្ត្រីដើម្បីប្រកបការងារទៅតាមឋានានុក្រមរបស់ខ្លួនដើម្បីធានាការអនុវត្តរបបនេះឱ្យមានគុណភាព ប្រសិទ្ធភាព និងតម្លាភាព។ ដើម្បីបញ្ជាក់បានថាការអនុវត្តរបបហានិភ័យការងារផ្នែកហានិភ័យការងារដែលគ្រប់គ្រងដោយ ប.ស.ស. ប្រកបដោយគុណភាព ប្រសិទ្ធភាព និងតម្លាភាព លុះត្រាតែបុគ្គលគ្រប់រូបមានការយល់ដឹងអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលគ្រប់គ្រងរបបសន្តិសុខផ្នែកហានិភ័យការងារនេះ។ យើងក៏ត្រូវក្រឡេកទៅមើលប្រភពច្បាប់នានាដែលបានចែងសម្រាប់អនុវត្ត និងគ្រប់គ្រងរបបសន្តិសុខផ្នែកហានិភ័យការងារមុនពេលច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩ ត្រូវបានដាក់អនុម័តឱ្យប្រើប្រាស់ជាផ្លូវការ។ នៅក្នុងមានសារណានេះនឹងបកស្រាយច្បាប់សារធាតុមួយចំនួនដែលជាប្រភពក្នុងការបង្កើតផ្នែកនេះឡើង រួមមានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារឆ្នាំ២០០២ អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមឆ្នាំ២០០៧ និងច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩។

នៅក្នុងច្បាប់កម្ពុជាក៏បានបែងចែកប្រភេទផ្នែកហានិភ័យការងារផងដែរ ដោយស្របតាមមាត្រា១ វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីបេឡាជាតិរបបសន្តិសុខសង្គមឆ្នាំ២០០២ និងយោងតាមឧបសម្ព័ន្ធនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមនិយមន័យនៃវាក្យសព្ទដែលប្រើនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម ប្រភេទនៃផ្នែកហានិភ័យការងារមានគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ។ ជាមួយគ្នានេះដែល គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ ត្រូវបានបែងចែកនូវការធានារ៉ាប់រងទៅលើកម្មវត្ថុខុសគ្នា ថែមទាំងភាពការបង្កឱ្យមានហានិភ័យការងារក៏មានលក្ខខណ្ឌការងារ។

[7] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩, មាត្រា៦០។

## ១.១. សញ្ញាណគតិយុត្តនៃរបបសន្តិសុខសង្គម

### ១.១.១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

#### ១.១.១.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាថ្មីបានអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយសភាធម្មនុញ្ញដែលកើតចេញពីការបោះឆ្នោតរៀបចំដោយអង្គការ សហប្រជាជាតិ ពីឆ្នាំ១៩៩៣ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។[8] បច្ចុប្បន្ននេះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើវិសោធនកម្មចំនួន ៩លើក ដើម្បីធានាក្នុងគ្រប់កាលៈទេសៈនូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមស្របតាមតម្រូវការនៃភាពចាំបាច់។ បើទោះបីជាមានការធ្វើវិសោធនកម្មចំនួន៩លើកក៏ដោយ យើងឃើញថាមាត្រា៧៥ នៃរដ្ឋធម្មនុញ្ញដែលបានចែងអំពីការចាត់តាំងឱ្យមានរបបសន្តិសុខសង្គមដល់កម្មករ និងនិយោជិត នៅតែរក្សាដោយគ្មានការកែប្រែនោះ។ ការចែងអំពីរបបសន្តិសុខសង្គមនៅក្នុងច្បាប់កំពូលកម្ពុជា បានឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់របស់រដ្ឋមកកាន់កម្មករនិយោជិតនានា ដោយបង្ហាញអំពីកាតព្វកិច្ចរបស់រដ្ឋក្នុងការផ្តល់នូវសេវាសន្តិសុខសង្គមយ៉ាងទូលំទូលាយជូនទៅដល់ជនរងគ្រោះទាំងនោះ។

#### ១.១.១.២.ច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧

ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ដែលបានអនុម័តដោយសភានៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១។ នៅក្នុងជំពូកទី ៩ នៃច្បាប់ស្តីពីការងារបានចែងអំពីគ្រោះថ្នាក់ការងារបានកំណត់អំពីនិយមន័យគ្រោះថ្នាក់ការងារ ថាតើគ្រោះថ្នាក់ដែលកើតឡើងក្នុងកាលៈទេសៈអ្វីខ្លះ ដែលត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ។ ខ្លឹមសារនៅក្នុងមាត្រា២៤៨ បានកំណត់ថា ជំងឺបណ្តាលមកពីវិជ្ជាជីវៈទាំងអស់ដូចមានបញ្ជាក់ក្នុងច្បាប់នេះ និងគ្រោះថ្នាក់នៅពេលធ្វើដំណើរពីលំនៅដ្ឋានត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ហើយទទួលបានការជួសជុលដូចគ្នាដែរ។ នៅពេលដែលកម្មករនិយោជិតត្រូវបានទទួលរងគ្រោះថ្នាក់ដែលចាត់ទុកថាជាគ្រោះថ្នាក់ការងារ នៅក្នុងច្បាប់ស្តីពីការងារឆ្នាំ១៩៩៧នេះ គឺនាយកសហគ្រាសផ្ទាល់មានកាតព្វកិច្ចក្នុងការទទួលខុសត្រូវទៅលើបុគ្គលិករបស់ខ្លួន និងមានតួនាទីក្នុងការចាត់វិធានការបង្ការគ្រោះថ្នាក់ការងារផ្សេងៗកុំឱ្យកើតឡើងនៅពេលអនាគត។[9] នៅក្នុងច្បាប់នេះបានផ្តល់នូវអត្ថប្រយោជន៍ជូនដល់អ្នករងគ្រោះថ្នាក់ការងាររួមមាន មានសិទ្ធិទទួលការពិនិត្យព្យាបាលជំងឺ (ការផ្តល់ជាវត្ថុ ការព្យាបាលជំងឺ និងការផ្តល់ថ្នាំ

[8] មន្ត្រីការិយាល័យព័ត៌មានវិទ្យា នៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.(២០២២).*ប្រវត្តិក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*.ដកស្រង់ចេញពីhttps://www.ccc.gov.kh/historyccc_kh.php ឆ្នាំ២០២២។

[9] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧, មាត្រា២៤៩ និងមាត្រា ២៥០។

ព្រមទាំងកន្លែងសម្រាកព្យាបាលជាដើម) និងការព្យាបាលខាងវះកាត់ និងផ្តល់បន្ថែមវត្ថុណាដែលចាំបាច់បន្ថែមពីគ្រោះថ្នាក់ទាំងនោះ។[10] នៅក្នុងកំឡុងពេលបង្កើតច្បាប់នេះ រាជរដ្ឋាភិបាលមានគម្រោងបង្កើតច្បាប់ដោយឡែកមួយក្នុងការគ្រប់គ្រងរបបទូទៅមួយខាងការរ៉ាប់រងជាកាតូកិច្ចចំពោះគ្រោះថ្នាក់ការងារ ដែលគ្រោះថ្នាក់ការងារនោះនឹងធ្វើការផ្លាស់ប្តូរដែលត្រូវស្ថិតនៅក្រោមការរ៉ាប់រងរបស់បេឡាជាតិសន្តិសុខសង្គមវិញ។[11] ហេតុដូចនេះហើយយោងតាមមាត្រា២៥៧ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ បានចែងថាបទបញ្ញាទាំងឡាយជាធរមាននៅពេលនោះត្រូវអនុវត្តបាន រហូតដល់ទំរាំមានការប្រកាសឱ្យប្រើនូវអត្ថបទច្បាប់ស្តីពីបទបញ្ញាទាំងឡាយនៃការរ៉ាប់រងខាងសង្គមកិច្ចសម្រាប់ហានិភ័យខាងវិជ្ជាជីវៈ។

### ១.១.១.៣. ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារឆ្នាំ ២០០២

ដោយអនុលោមតាមមាត្រា ៧៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាមាត្រា២៥៦ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ផងនោះ។ នៅឆ្នាំ២០០២ អង្គការនីតិបញ្ញត្តិបានអនុម័តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារឆ្នាំ២០០២ ត្រូវបានអនុម័តនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី២។ ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០០២ នេះ បង្កើតឱ្យមានរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយទទួលបន្ទុកផ្តល់តាវកាលិកផ្នែកហានិភ័យការងារ ចំពោះគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ។ ច្បាប់នេះបង្កើតឡើងក្នុងគោលបំណងការពារបុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារ ឆ្នាំ ២០០២ ដែលជនទាំងនោះត្រូវដាក់បញ្ចូលឱ្យនៅក្នុងរបបសន្តិសុខសង្គមតាមច្បាប់នេះ ដោយមិនមានបែងចែកពីពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា គំនិតនយោបាយជាតិកំណើតដើមកំណើតសង្គម និងបូក្ខមទាំងការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីពគឺ ៖[12]

- កម្មករនិយោជិតទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារប្រសិនបើជនទាំងនោះ ធ្វើសកម្មភាពការងារនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍សម្រាប់និយោជកម្នាក់ ឬច្រើននាក់ ដោយមិនគិតដល់ប្រភេទ ទម្រង់និងសុពលភាពនៃកិច្ចសន្យា ឬប្រភេទនិងចំនួននៃប្រាក់ឈ្នួលដែលជននោះបានធ្វើឬ បានទទួលឡើយ។

[10] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧, មាត្រា២៥៤។

[11] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧, មាត្រា២៥៦។

[12] ច្បាប់ស្តីពីបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារឆ្នាំ២០០២, មាត្រា ៤។

- កម្មករនិយោជិតរដ្ឋ កម្មករនិយោជិតនៃអង្គការសាធារណៈ និងបុគ្គលិកទាំងអស់ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឬលក្ខន្តិកៈទូត ព្រមទាំងភ្នាក់ងារក្រុមរាជការសាធារណៈដែលតែងតាំងដោយបណ្តោះអាសន្ន។
- សិស្សសាលាវិជ្ជាជីវៈ ជនដែលដាក់ឱ្យធ្វើការងារនៅក្នុងមណ្ឌលបណ្តុះបណ្តាលសម្របសម្រួលនិងអប់រំវិជ្ជាជីវៈសារឡើងវិញនិងកូនជាង ត្រូវចាត់ទុកដូចជាកម្មករនិយោជិត ដូចមានចែងនៅក្នុង វាក្យ-ខ័ណ្ឌទី១នៃមាត្រានេះដែរ។ បែបបទសម្រាប់អនុវត្តបទប្បញ្ញត្តិផ្នែកនេះ ត្រូវកំណត់ដោយប្រកាស នៃរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម។
- ជនដែលប្រកបមុខរបរក្នុងវិជ្ជាជីវៈសេរីដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម។
- កម្មករនិយោជិតធ្វើការម្តងម្កាល ឬតាមរដូវ។ បែបបទចាំបាច់ដោយឡែកផ្សេងទៀតសម្រាប់ការអនុវត្តបទប្បញ្ញត្តិនៃផ្នែកនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម។
- សមាសភាពនឹងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបច្ចេកទេស ត្រូវកំណត់ដោយអនុក្រឹត្យ។

ចំពោះផ្នែកហានិភ័យការងារនៅក្នុងច្បាប់នេះបានចាត់ទុកគ្រោះថ្នាក់ការងារ ជាគ្រោះថ្នាក់ដែលធ្លាក់លើរូបរាងកាយកម្មករនិយោជិតដោយធ្វើការ ឬក្នុងពេលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសពីកម្មករនិយោជិត ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិត ក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វីនៅទីកន្លែងណាក៏ដោយ។[13] ជារួមមកគ្រោះថ្នាក់ការងារណាដែលធ្លាក់លើរូបកាយកម្មករនិយោជិត ក្នុងពេលដែលសាមីជនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ គ្រោះថ្នាក់ត្រូវបានកំណត់ថាជាគ្រោះថ្នាក់ការងារផងដែរ។[14] លើសពីនេះទៅទៀត ចំពោះផ្នែកហានិភ័យការងារនៅក្នុងច្បាប់នេះបានរាប់បញ្ចូលជំងឺដែលបណ្តាលមកពីវិជ្ជាជីវៈ ដែលកើតចេញពីមុខររបរប្រើកម្លាំងកាយ មុខរបរដែលប៉ះពាល់ដោយជាតិពុល និងមុខរបរដែលអនុវត្តនៅក្នុងលក្ខខណ្ឌ ឬតំបន់មានលក្ខណៈមិនប្រក្រតី ដែលនាំឱ្យអ្នកធ្វើការកើតជំងឺផ្សេងៗ

[13] ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារឆ្នាំ២០០២, មាត្រា ១២។

[14] ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារឆ្នាំ២០០២, មាត្រា ១២។

បន្ទាប់ពីការផ្ដល់យោបល់ពីក្រុមប្រឹក្សាបច្ចេកទេស។[15] នៅក្នុងចំណុចនេះជំងឺដែលគេបានប្រកាសថាជាហានិភ័យការងារក្រោយពីកាលបរិច្ឆេទដែលកម្មករនិយោជិតបានឈប់ធ្វើការហើយនោះ ក៏អាចបើកសិទ្ធិឱ្យអ្នករងគ្រោះទទួលតាវកាលិកសម្រាប់ហានិភ័យការងារបានដែរ បើការប្រកាសនោះស្ថិតក្នុងកំឡុងពេលដែលមានបញ្ជាក់ក្នុងបញ្ជីនៃជំងឺវិជ្ជាជីវៈ ដែលមានចែងក្នុងវាក្យខណ្ឌទី១ ដូចដែលបានរៀបរាប់ខាងលើ។

បទប្បញ្ញត្តិដែលបានចែងនៅក្នុងច្បាប់នេះ បានផ្ដល់សិទ្ធិដល់អ្នករងគ្រោះដោយគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ នៅពេលមានគ្រោះថ្នាក់កើតឡើងចំពោះខ្លួន ត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬអ្នកតំណាងនៃនិយោជកនោះ អំពីគ្រោះថ្នាក់ដែលធ្លាក់មកលើខ្លួន លើកលែងតែក្នុងករណីប្រធានសក្តិ ឬការមិនមានលទ្ធភាពជាស្ថាពរ ឬក៏មានមូលហេតុសមហេតុផល។ កាតព្វកិច្ចដូចគ្នានេះដែរ បើក្នុងករណីមានគ្រោះថ្នាក់បណ្ដាលឱ្យបាត់បង់ជីវិត ត្រូវធ្លាក់ទៅលើអ្នកសិទ្ធិវន្ត។[16] បន្ទាប់មកនិយោជកមានកាតព្វកិច្ចជូនដំណឹងទៅបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីឱ្យអង្គភាពនេះអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្ដល់តាវកាលិកនៃហានិភ័យការងារ ដែលអត្ថប្រយោជន៍ដែលត្រូវជូនជនរងគ្រោះនោះរួមមាន៖[17]

- ការថែទាំ និងព្យាបាលមុខរបួសបើទោះបីគ្រោះថ្នាក់នោះបណ្ដាលឱ្យមានការអាក់ខានធ្វើការក្ដី ឬគ្មានក្ដី
- ការផ្ដល់ប្រាក់បំណាច់ប្រចាំថ្ងៃ ក្នុងករណីគ្រោះថ្នាក់នោះបណ្ដាលឱ្យជនរងគ្រោះបាត់បង់សមត្ថភាពការងារជាបណ្ដោះអាសន្ន
- ការផ្ដល់ប្រាក់ធនលាភ ឬប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍
- ការផ្ដល់ប្រាក់វិភាជន៍ជាសោហ៊ុយសម្រាប់បូជាសព និងធនលាភចំពោះឧត្តរជីវីនៃជនរងគ្រោះ។

យ៉ាងណាមិញ ចំពោះជំពូកទី៥បានក៏ចែងអំពីទោសប្បញ្ញត្តិក្នុងករណីបុគ្គលដែលពាក់ព័ន្ធបានប្រព្រឹត្តអំពើល្មើសនៃច្បាប់នេះនឹងត្រូវទទួលការផ្ដន្ទាទោសចំពោះមុខច្បាប់ទាំងពិន័យជាប្រាក់ ឬដាក់ពន្ធនាគារទៅតាមកម្រិតនៃបទល្មើសនីមួយៗ។

### ១.១.១.៤. អនុក្រឹត្យលេខ ១៦ អនក្រ.បកស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

អនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម។ អនុក្រឹត្យនេះ បានបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាផ្នែកសាធារណៈមានលក្ខណៈសង្គម មានឈ្មោះថា «បេឡាជាតិរបបសន្តិសង្គម» សរសេរជាអក្សរកាត់ «ប.ស.ស.»។ ប.ស.ស.

[15] ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារឆ្នាំ២០០២, មាត្រា ១៣ វាក្យខណ្ឌទី១។
[16] ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារឆ្នាំ២០០២, មាត្រា ១៤ វាក្យខណ្ឌទី១។
[17] ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារឆ្នាំ២០០២, មាត្រា ១៥។

ត្រូវស្ថិតនៅក្រោមអាណាព្យាបាល បច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប.ស.ស. មានស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ។[18] ប.ស.ស. គឺជានីតិបុគ្គលសាធារណៈដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ។ ប.ស.ស.ត្រូវស្ថិតនៅក្រោមអានុភាពនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារ។[19]

ប.ស.ស. មានភារកិច្ចដូចខាងក្រោម៖[20]

- គ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។
- ធានាផ្តល់ឱ្យបានសមស្របនូវតាវកាលិកទាំងឡាយសម្រាប់សមាជិកនៃ ប.ស.ស. ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេល ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ មាតុភាព ជាដើម។
- ប្រមូលភាគទានពីសមាជិកនៃ ប.ស.ស. និងនិយោជិក។
- សម្របសម្រួល និងរៀបចំឱ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន។
- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បី៖
  - អប់រំផ្សព្វផ្សាយអំពីរបៀបបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ
  - ចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខ និងអនាម័យការងារ។
- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវ និងអង្កេតហានិភ័យការងារ។
- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម។

នៅក្នុងអនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមបានបែងចែកអំពីហេដ្ឋារចនាសម្ព័ន្ធនៃផ្នែកនីមួយៗ ដែលក្នុងនោះមន្ត្រីត្រូវបម្រើការងារឱ្យស្របតាមផ្នែក និងមុខងារដែលទទួលបន្ទុកខុសៗគ្នា។

[18] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ១។
[19] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ២។
[20] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ៣។

### ១.១.១.៤.១. រដ្ឋបាលបេឡាជាតិរបបសន្តិសង្គម

រដ្ឋបាលបេឡាជាតិរបបសន្តិសង្គម មានក្រុមប្រឹក្សាភិបាល និងអង្គការប្រតិបត្តិនៃ ប.ស.ស.។ ចំពោះក្រុមប្រឹក្សាភិបាលប.ស.ស. ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានអំណាចដើម្បីគ្រប់គ្រងគ្រឹះស្ថានក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងក្នុងក្របខ័ណ្ឌនៃបទបញ្ជាផ្ទៃក្នុងរបស់ ប.ស.ស.។ ក្រុមប្រឹក្សាភិបាលនេះមានសមាសភាពដូចខាងក្រោម៖[21]

- តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ រូប សមាជិក
- តំណាងក្រសួងសុខាភិបាល ១ រូប សមាជិក
- តំណាងនិយោជក ២ រូប សមាជិក
- តំណាងកម្មករនិយោជិតសមាជិកនៃ ប.ស.ស ២ រូប សមាជិក
- នាយកនៃ ប.ស.ស. សមាជិកស្វ័យប្រវត្តិ

ក្រុមប្រឹក្សាភិបាលនៃប.ស.ស. មានបេសកកម្មក្នុងការតម្រង់ទិស និងត្រួតពិនិត្យដំណើរប្រព្រឹត្តទៅ ប.ស.ស. ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលមានភារកិច្ចដូចតទៅ៖[22]

- អនុវត្តថវិកាប្រចាំឆ្នាំរបស់ ប.ស.ស. ជាពិសេសសម្រាប់តាវកាលិកនៃផ្នែកសន្តិសុខសង្គមនីមួយៗ ផ្នែករដ្ឋបាល និងផ្នែកសកម្មភាពសុខាភិបាល និងសង្គមកិច្ច
- ពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំស្តីពីការងារគ្រប់គ្រង និងហិរញ្ញវត្ថុនៃ ប.ស.ស.
- ពិនិត្យ និងសម្រេចលើបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលនៃ ប.ស.ស.
- ពិនិត្យ និងសម្រេចរចនាសម្ព័ន្ធ និងភារកិច្ចរបស់អង្គភាពចំណុះនៃ ប.ស.ស.
- កំណត់អំពីបែបបទនៃការជ្រើសរើស ការបញ្ឈប់ពីការងារ ការដំឡើងឋានៈ ឬមុខតំណែង ការដាក់វិន័យ ឬ ការផ្តល់លាភការនៃបុគ្គលិក តាមសំណើរបស់នាយកនៃ ប.ស.ស.
- សម្រេចចំនួនក្របខ័ណ្ឌនៃបុគ្គលិកដែលអនុញ្ញាតសម្រាប់ ប.ស.ស.
- ពិនិត្យ និងសម្រេចលើសំណើអត្រាភាគទាននៃផ្នែកសន្តិសុខសង្គមនីមួយៗ
- ពិនិត្យ និងសម្រេចលើសំណើការកំណត់ប្រភេទ និងអត្រាតាវកាលិក
- សម្រេចអំពីកិច្ចសន្យាស្តីពីលទ្ធកម្មនៃ ប.ស.ស.

[21] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ៤។

[22] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ៥។

- កំណត់កម្មវិធី និងផែនការវិនិយោគនៃ ប.ស.ស.
- វាយតម្លៃនូវលទ្ធផលការងារនៃ ប.ស.ស. និងលើកវិធានការកែលម្អការអនុវត្ត
- សហការជាមួយក្រុមប្រឹក្សាបច្ចេកទេសនៃ ប.ស.ស. សិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ បច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឱ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច ។

ចំណែកឯអង្គការប្រតិបត្តិនៃប.ស.ស. ក៏ស្ថិតនៅក្នុងរដ្ឋបាលបេឡាជាតិរបបសន្តិសង្គម ដែលមាននាយកនៃ ប.ស.ស. ត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្រ្តីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នាយកនៃប.ស.ស. មានភារកិច្ចចាត់ចែង គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ ប.ស.ស.។[23] នាយកនៃប.ស.ស. ត្រូវបានទទួលអំណាចចាំបាច់សម្រាប់ដំណើរការប្រចាំថ្ងៃដើម្បីមានលទ្ធភាពពេញលេញ ក្នុងការដឹកនាំគ្រឹះស្ថានស្របតាមច្បាប់ និងជាតំណាង ប.ស.ស. ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ អំណាច នេះត្រូវបានប្រគល់ឱ្យតាមរយៈបទបញ្ជាផ្ទៃក្នុងរបស់ប.ស.ស.និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស .។

ក្នុងក្របខ័ណ្ឌនៃអំណាចនេះ នាយកនៃប.ស.ស. មានភារកិច្ចសំខាន់ៗដូចតទៅៈ[24]

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស.
- រៀបចំឯកសារដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច
- ចាត់ចែងអនុវត្តគ្រប់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងរាយការណ៍តាមដំណាក់កាលនីមួយៗជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាព និងលទ្ធផលការងាររបស់ ប.ស.ស.
- ទទួលបន្ទុកដឹកនាំ ប.ស.ស. ផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ប.ស.ស. ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង សម្រេច
- គ្រប់គ្រងបណ្តាភ្នាក់ងារ ឬ មន្រ្តីគ្រប់រូបរបស់ ប.ស.ស. ដោយគោរពតាម លក្ខន្តិកៈ ឬ ច្បាប់ជាធរមាន និង តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- លើកសំណើជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈដាក់វិន័យ ឬ ផ្តល់លាភការដល់បុគ្គលិករបស់ ប.ស.ស. ដែលនៅក្រៅក្របខ័ណ្ឌនៃមន្រ្តីរាជការស៊ីវិល
- លើកសំណើជូនរដ្ឋមន្រ្តីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពិនិត្យ និងសម្រេច ចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈ ដាក់វិន័យ ឬផ្តល់លាភការដល់មន្រ្តីរាជការនៃប.ស.ស. ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃមន្រ្តីរាជការស៊ីវិល

---

[23] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ១១។

[24] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ១២។

- ធ្វើជាតំណាងនៃ ប.ស.ស. ចំពោះការតវ៉ា ឬការប្តឹងជំទាស់នានាទាក់ទងដល់ប្រតិបត្តិការរបស់ ប.ស.ស. និង ទទួលខុសត្រូវចំពោះមុខច្បាប់លើគ្រប់កិច្ចការពារផលប្រយោជន៍របស់ ប.ស.ស. ។

នាយកនៃប.ស.ស. មានសិទ្ធិផ្ទេរអំណាចខ្លះ ឬ ទាំងអស់រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាស្របតាមលក្ខខណ្ឌដែលកំណត់ ក្នុងបទបញ្ជាផ្ទៃក្នុង ឬ កំណត់ដោយក្រុមប្រឹក្សាភិបាល។

### ១.១.១.៤.២. ការគ្រប់គ្រងហិរញ្ញវត្ថុ

ចំពោះផ្នែកការគ្រប់គ្រងហិរញ្ញវត្ថុមាន កិច្ចការគណនេយ្យ ប្រភពធនធាន ការចំណាយ ប្រាក់ត្រៀមបម្រុង មូលនិធិបម្រុង និងការវិភាគសន្តិសុខសង្គម។ ក្នុងនោះ ប.ស.ស. កាន់កាប់គណនេយ្យស្របតាមគោលការណ៍គណនេយ្យសាធារណៈ និងតាមវិធានគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដោយគណនេយ្យមានភារកិច្ចដូចជា ប្រមូលចំណូល បើកប្រាក់ចំណាយ រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់ ប.ស.ស. និងរក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ។[25]

ប្រភពធនធាន ប.ស.ស. មានដូចខាងក្រោមៈ[26]

- ធនធានដំបូងដែលរដ្ឋផ្តល់សម្រាប់ការបង្កើត ប.ស.ស. ។
- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈដែលមានចែងក្នុងថវិការដ្ឋដូចជាឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ។
- ភាគទានរបស់សមាជិកន ប.ស.ស. និង និយោជក ដែលទុកសម្រាប់ហិរញ្ញប្បទានលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ។
- ប្រាក់ពិន័យពីការយឺតយូរក្នុងការបង់ភាគទាន ឬការផ្តល់តារាងបៀវត្ស ព្រមទាំងការប្រាក់ពីការយឺតយូរនោះ។
- ផលចំណេញដែលបានមកពីការវិនិយោគ។
- អំណោយ និងអច្ច័យទានផ្សេងៗ ។
- ប្រភពធនធានដទៃទៀតដែល ប.ស.ស. អាចទទួលបានស្របតាមច្បាប់។

ការចំណាយរបស់ប.ស.ស. រួមមានៈ[27]

- ការចំណាយសម្រាប់តាវកាលិកនៃផ្នែកនីមួយៗ។
- ការចំណាយសម្រាប់ការងាររដ្ឋបាលនៃ ប.ស.ស.។

[25] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ១៧, ១៨។
[26] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ២០។
[27] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ២១។

- ការចំណាយសម្រាប់សកម្មភាពខាងសុខាភិបាល និងសង្គមកិច្ច។
- ការចំណាយលើការវិនិយោគដើម្បីជាប្រយោជន៍របស់ ប.ស.ស.។

ទម្រង់ និងបែបបទនៃការចំណាយខាងលើ ត្រូវចែងលំអិតក្នុងប្រកាសរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាល វិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ ប.ស.ស.។ ប្រាក់ត្រៀមបម្រុងអប្បបរមាសម្រាប់ផ្នែកហានិភ័យការងារត្រូវស្មើនឹងចំនួនទឹកប្រាក់ចំណាយសម្រាប់ធនលាភ ដែលបានឧបត្ថម្ភកន្លងទៅ និង ១/២( មួយភាគពីរ) នៃប្រាក់ចំណាយសម្រាប់តាវកាលិកដទៃក្រៅពីធនលាភក្នុងអំឡុងពេល២(ពីរ)ឆ្នាំចុងក្រោយ។[28] មូលនិធិបម្រុងត្រូវបង្កើតឱ្យមានមូលនិធិបម្រុងរួមមួយសម្រាប់ការចំណាយនៃផ្នែកទាំងឡាយរបស់របបសន្តិសុខសង្គម។ មូលនិធិនេះមិនត្រូវតិចជាង២(ពីរ)ដង នៃប្រាក់ចំណាយជាមធ្យមប្រចាំខែរបស់ ប.ស.ស. នៅក្នុងអំឡុងឆ្នាំចុងក្រោយឡើយ ។[29]

ការវិភាគសន្តិសុខសង្គម ដែលប.ស.ស.ត្រូវធ្វើវិភាគហិរញ្ញវត្ថុសម្រាប់របបសន្តិសុខសង្គមយ៉ាងយូរបីឆ្នាំម្តង។[30] ក្នុងករណីដែលការវិភាគ នេះបង្ហាញថាអាចមានគ្រោះថ្នាក់ដោយសារមានអតុល្យភាពហិរញ្ញវត្ថុនៅក្នុងផ្នែកណាមួយ ប.ស.ស.ត្រូវស្នើសុំធ្វើការ កែតម្រូវអត្រាភាគទាន ឬអាយុចូលនិវត្តន៍ ដើម្បីអាចធានាបាននូវនិរន្តរភាពក្នុងកិច្ចដំណើការរបស់ប.ស.ស.។ រដ្ឋត្រូវផ្តល់ការឧបត្ថម្ភទ្រទ្រង់ឱ្យប.ស.ស.បន្តនិរន្តរភាពនៅពេលជួបប្រទះឱនភាពថវិកា។

### ១.១.១.៤.៣. ភាគទាន និងតាវកាលិកសន្តិសុខសង្គម

អត្រានៃភាគទាន និងតាវកាលិកសម្រាប់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃប.ស.ស. ។[31]

### ១.១.១.៦. ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩

ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩ ត្រូវបានធ្វើសោធន៍កម្មចេញពីច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារឆ្នាំ២០០២។ បន្ទាប់ពីច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩ ត្រូវបានអនុម័តដោយសភាឱ្យប្រើប្រាស់ជាផ្លូវការ ជាហេតុធ្វើឱ្យបញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០០២ ត្រូវបាននរាករណ៍ដោយជំនួសដោយច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩ វិញ។ ច្បាប់

[28] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ២២។

[29] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ២៣។

[30] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ២៤។

[31] អនុក្រឹត្យលេខ ១៦ អនក្រ.បកចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, មាត្រា ២៥ និង២៦។

ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩ លេខ នស/រកម/១១១៩/០១៨ នេះត្រូវបានសភាអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ ដែលមុខងាររបស់ច្បាប់នេះបង្កើតឡើងក្នុងការអនុវត្តក៏មិនខុសគ្នាទៅនឹងច្បាប់ចាស់ដែលត្រូវបាននរាករណ៍នោះទេ មានន័យការធ្វើវិសោធនកម្មនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមក្នុងផ្នែកបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ គឺមានគោលបំណងក្នុងការពង្រីកវិសាលក្នុងការអនុវត្តចំពោះបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះដែលមុខងារទាំងនេះត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជក ត្រូវមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះ។[32] នៅក្នុងជំពូកទី៦ ផ្នែកទី៣ បានចែងអំពីអត្ថប្រយោជន៍ដែលទទួលបានសម្រាប់ផ្នែកហានិភ័យការងារសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះដូចជាៈ[33]

- សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារ ត្រូវអនុវត្តដូចគ្នានឹងការផ្តល់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារ សម្រាប់បុគ្គលនៃវិស័យសាធារណៈ ដែលមានចែងក្នុងមាត្រា៦៥នៃច្បាប់នេះ។
- ប្រាក់បំណាច់សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន នៅក្នុងរយៈពេលនៃការសម្រាកព្យាបាលមុនរបួសឬជំងឺដែលបណ្តាលមកពីហានិភ័យការងារនៅតាមមូលដ្ឋានសុខាភិបាល និងរយៈពេលសម្រាកក្រោយការចេញពីមូលដ្ឋានសុខាភិបាល តាមវេជ្ជបញ្ជាដែលចេញដោយគ្រូពេទ្យផ្លូវការឬគ្រូពេទ្យទទួលស្គាល់ដោយ ប.ស.ស. សាមីជនរងគ្រោះមានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន។
- ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវពិត ចាប់ពីថ្ងៃទីពីរដែលសាមីជនរងគ្រោះថ្នាក់រហូតមុខរបួសឬជំងឺជាសះស្បើយ ឬទទួលមរណភាព ដោយគិតរួមទាំងរយៈពេលដែលគ្រូពេទ្យព្យាបាលអនុញ្ញាតឱ្យឈប់សម្រាកបន្ទាប់ពីចេញពី មូលដ្ឋានសុខភិបាល ផងដែរ។ ប្រាក់ឈ្នួលរបស់សាមីជនសម្រាប់ថ្ងៃកការងារដំបូងជាបន្ទុករបស់និយោជក។
- ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវស្មើ នឹង៧០%នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីជន ក្នុងរយៈពេល៦ខែចុងក្រោយ។ ក្នុងករណីដែលរយៈពេលបំពេញការងាររបស់សាមីជនតិចជាង៦(ប្រាំមួយ)ខែ ប្រាក់ប្រចាំថ្ងៃ ត្រូវគិតតាមស្ថានភាពជាក់ស្តែងៗ។

[32] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩, មាត្រា៣ វាក្យខណ្ឌទី២ និងមាត្រា៧។

[33] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩, មាត្រា៧៥ដល់មាត្រា៨០។

- ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍អនុវត្តដូចមានបញ្ញត្តក្នុងមាត្រា៧១ក្នុងច្បាប់នេះ។
- វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវអនុវត្តដូចមានបញ្ញត្តក្នុងមាត្រា៧២ក្នុងច្បាប់នេះ។
- វិភាជន៍បូជាសព និងធនលាភឧត្តរជីវី ត្រូវអនុវត្តដូចមានបញ្ញត្តក្នុងមាត្រា៧៣នៃច្បាប់នេះ។
- សេវាស្តារនីតិសម្បទា ត្រូវអនុវត្តដូចមានបញ្ញត្តក្នុងមាត្រា៧៤នៃច្បាប់នេះ។

### ១.១.២. ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច

#### ១.១.២.១. ក្រុមប្រឹក្សាជាតិគាំពារសង្គម

ក្រុមប្រឹក្សាជាតិគាំពារសង្គមធ្វើការកំណត់រាល់ប្រតិបត្តិការសន្តិសុខសង្គមត្រូវស្ថិតនៅក្រោមការសម្របសម្រួល តាមដាន និងតម្រង់ទិសក្នុងកម្រិតគោលនយោបាយនិងយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គមត្រូវកំណត់ដោយព្រះរាជក្រឹត្យ។[34]

#### ១.១.២.២. និយ័តករសន្តិសុខសង្គម

និយ័តករសន្តិសុខសង្គមត្រូវបានបង្កើតនិយ័តករសន្តិសុខសង្គមដែលមានតួនាទី និងភារកិច្ចដូចជា៖[35]

- កំណត់បទប្បញ្ញត្តិប្រុងប្រយ័ត្ន ស្តង់ដារប្រតិបត្តិការ វិធានចាំបាច់នានា និងគោលការណ៍ណែនាំស្តីពីវិនិយោគមូលនិយោគមូលនិធិសន្តិសុខសង្គម។
- តាមដានស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម។
- បង្កើតយន្តការពារសមាជិក និងផ្សះផ្សាវិវាទនៅពេលមានទំនាស់។
- ត្រួតពិនិត្យអនុលោមភាព ដើម្បីធានាថាប្រតិបត្តិការនៅក្នុងការផ្តល់សេវាសន្តិសុខសង្គមប្រព្រឹត្តទៅដោយតម្លាភាព គណនេយ្យភាព និងចីរភាពហិរញ្ញវត្ថុ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់និយ័តករសន្តិសុខសង្គមត្រូវកំណត់ដោយអនុក្រឹត្យ។

#### ១.១.២.៣. បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)

ប.ស.ស. ជាគ្រឹះស្ថានសាធារណៈដែលបានបង្កើតដោយអនុក្រឹត្យអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៦ និងព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈ។ អនុក្រឹត្យស្តីពីការបង្កើត ប.ស.ស. ត្រូវបានអនុម័តនៅឆ្នាំ២០០៧ ដែលបង្កើត

[34] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩, មាត្រា១០។

[35] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩, មាត្រា១១។

ឡើងដើម្បីជំនួសនាយកដ្ឋានសន្តិសុខសង្គម។ ប.ស.ស. ជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។[36] ប.ស.ស. ជាគ្រឹះស្ថានសាធារណៈ រដ្ឋបាលដែលត្រូវបង្កើតដោយព្រះរាជក្រឹត្យ ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បច្ចុប្បន្ននេះអគារស្នាក់ការកណ្តាលបេឡាជាតិសន្តិសុខសង្គមនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានអាសយដ្ឋាននៅភូមិបន្លាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

### ១.១.២.៣.១. ភារកិច្ចរបស់បេឡាជាតិសន្តិសុខសង្គម

ប.ស.ស. មានភារកិច្ចដូចខាងក្រោម៖[37]

- គ្រប់គ្រង និងចាត់ចែងផ្នែកទាំងអស់នៃរបបសន្តិសុខសង្គមដែលកំណត់ដោយច្បាប់នេះ។
- ធានាផ្តល់តាវកាលិកសន្តិសុខសង្គមសម្រាប់សមាជិក ប.ស.ស. ក្នុងគោលដៅជួយសម្រាលការលំបាកក្នុងជីវភាពនៅពេលជួបប្រទះហានិភ័យជាយថាហេតុនានាជាអាទិ៍ ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ និកម្មភាពការងារ មាតុភាព ជំងឺ ឬគ្រោះថ្នាក់ ព្រមទាំងយថាភាពដទៃផ្សេងទៀត។
- ប្រមូលនិងគ្រប់គ្រងភាគទានរបបសន្តិសុខសង្គមនៃផ្នែកនីមួយៗព្រមទាំងប្រភព ចំណូលដទៃផ្សេងទៀត។
- ចុះបញ្ជី និងគ្រប់គ្រងលេខសម្គាល់សមាជិក ប.ស.ស.។
- ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ ដោយសហគ្រាស គ្រឹះស្ថាន ឬអង្គភាព ពាក់ព័ន្ធដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ ប.ស.ស.។
- អប់រំ ផ្សព្វផ្សាយ និងត្រួតពិនិត្យការអនុវត្តវិធានការបង្ការហានិភ័យការងារ និងបង្ការ សុខភាពសម្រាប់សមាជិក ប.ស.ស.។
- សិក្សា ស្រាវជ្រាវ និងអង្កេតហានិភ័យការងារ។
- សិក្សាស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការកំណត់ប្រភេទជំងឺវិជ្ជាជីវៈ។
- ចុះកិច្ចព្រមព្រៀងនិងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល។
- សិក្សា វិភាគ និងវាយតម្លៃហិរញ្ញវត្ថុលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម។
- អនុវត្តសកម្មភាពពាក់ព័ន្ធនឹងសុខភាពនិងសង្គម ដែលពាក់ព័ន្ធនឹងអត្ថប្រយោជន៍ នៃសមាជិក ប.ស.ស.។

[36] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩, មាត្រា១២។

[37] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩, មាត្រា១៣។

- ចាត់ចែងនិងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម។

### ១.១.២.៣.២. ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម

ប.ស.ស. ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលមានសមាសភាពដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប សមាជិក
- តំណាងក្រសួងមុខងារសាធារណៈ ១រូប សមាជិក
- តំណាងក្រសួងសុខាភិបាល ១រូប សមាជិក
- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប សមាជិក
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក
- និយោជក ២រូប សមាជិក
- តំណាងសមាជិក ប.ស.ស. ២រូប សមាជិក
- អគ្គនាយក ប.ស.ស. សមាជិកអចិន្ត្រៃយ៍។

### ១.១.២.៣.៣. អង្គភាពប្រតិបត្តិនៃបេឡាជាតិសន្តិសុខសង្គម

ប.ស.ស. ត្រូវចាត់ចែង គ្រប់គ្រងការងារប្រចាំថ្ងៃដោយអគ្គនាយក១(មួយ)រូបដែលត្រូវ តែងតាំងដោយព្រះរាជក្រឹត្យ និងអគ្គនាយករងមួយចំនួនជាជំនួយការ អនុលោមតាមលិខិត បទដ្ឋានគតិយុត្តជាធរមាន។[38] ការត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ ប.ស.ស. ដែលមានកំណត់ក្នុងច្បាប់នេះជាសមត្ថកិច្ចរបស់អធិការសន្តិសុខសង្គម។ ការតែងតាំងនិងតួនាទីភារកិច្ចរបស់អធិការសន្តិសុខសង្គម ត្រូវកំណត់ដោយអនុក្រឹត្យ។

បុគ្គលិករបស់ ប.ស.ស. ជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលត្រូវបាន ផ្ទេរឬជ្រើសរើសថ្មីតាមសំណើរបស់អគ្គនាយក ប.ស.ស. និងបុគ្គលិកជាប់កិច្ចសន្យាដែល ស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈបុគ្គលិកនៃ ប.ស.ស. ស្របតាមច្បាប់ស្តីពីការងារ។

[38] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩, មាត្រា១៥។

## ១.២. សញ្ញាណនៃផ្នែកហានិភ័យការងារ

### ១.២.១. និយមន័យ

ហានិភ័យការងារ សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើង ដោយឥតគ្រោងទុកបណ្តាលមកពីគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ។[39]

### ១.២.២. ប្រភេទនៃហានិភ័យការងារ

#### ១.២.២.១. គ្រោះថ្នាក់ការងារ

គ្រោះថ្នាក់ការងារ សំដៅដល់ថ្នាក់ការងារដែលកើតឡើងដោយចៃដន្យ និងភ្លាមៗក្នុងពេលធ្វើការងារ ដោយធ្វើការងារឬនៅកន្លែងធ្វើការងារ ដោយមូលហេតុទាក់ទងនឹងកំហុសជនរងគ្រោះ ឬគ្មានកំហុសក៏ដោយ ដែលបណ្តាលឱ្យជនរងគ្រោះទទួលរងរបួសស្នាមជាយថាហេតុ។ គ្រោះថ្នាក់ការងារត្រូវចាត់ទុកជាហានិភ័យការងារ។[40]

#### ១.២.២.២. គ្រោះថ្នាក់ការងារក្នុងពេលធ្វើដំណើរ

គ្រោះថ្នាក់ការងារក្នុងពេលធ្វើដំណើរ សំដៅដល់ថ្នាក់ការងារដែលកើតឡើងពេលធ្វើដំណើរនៅលើកំណាត់ផ្លូវត្រង់រវាងលំនៅឋាន និងកន្លែងធ្វើការងារក្នុងចិរវេលាសមស្រប។ អធិការសន្តិសុខសង្គមមានឆន្ទានុសិទ្ធិក្នុងការចាត់ទុកគ្រោះថ្នាក់ពេលធ្វើដំណើរជាហានិភ័យការងារ ដោយផ្អែកលើហេតុផលជាក់ស្តែងដែលទទួលបានពីការអង្កេតលើករណីគ្រោះថ្នាក់នីមួយៗ។[41]

#### ១.២.២.៣. ជម្ងឺវិជ្ជាជីវៈ

ជម្ងឺវិជ្ជាជីវៈ សំដៅដល់សភាពនៃរោគសមុដ្ឋានឬការកើតរោគដែលពាក់ព័ន្ធនឹងការអនុវត្តការងារក្នុងមុខរបរណាមួយជាកំណត់ ពោលគឺរោគឬជំងឺដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងកត្តានានានៃការងារមានជាអាទិ៍ កំលុងពេលធ្វើការងារ កន្លែងធ្វើការងារ របៀបធ្វើការងារសារធាតុឬវត្ថុធាតុប្រើប្រាស់ក្នុងផលិតកម្ម បរិយាកាសនៃកន្លែងធ្វើការជាដើម ដែលអាចធ្វើឱ្យកើតរោគឬជំងឺទោះបីក្នុងកំលុងពេលដែលសាមីជនកំពុងបំពេញការងារឬមុខរបរ ឬក្រោយកំលុងពេលដែលលែងបំពេញការងារ ឬមុខរបរទាំងនោះក្តី។ ជំងឺវិជ្ជាជីវៈត្រូវ

[39] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩, ឧបសម្ព័ន្ធនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម និយមន័យនៃវាក្យសព្ទដែលប្រើនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម។

[40] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩, ឧបសម្ព័ន្ធនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម និយមន័យនៃវាក្យសព្ទដែលប្រើនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម។

[41] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩, ឧបសម្ព័ន្ធនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម និយមន័យនៃវាក្យសព្ទដែលប្រើនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម។

ចាត់ទុកជាហានិភ័យការងារ។ ជំងឺទូទៅ ទោះបីកើតនៅកន្លែងធ្វើការក៏ដោយក៏មិនត្រូវបានចាត់ទុកជាហានិភ័យការងារទេ។ [42]

[42] ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ ២០១៩, ឧបសម្ព័ន្ធនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម និយមន័យនៃវាក្យសព្ទដែលប្រើនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម។

# ជំពូកទី២

# នីតិវិធីក្នុងការទទួលបាននូវធានារ៉ាប់រង
# ផ្នែកហានិភ័យការងារ

# ជំពូកទី២

# នីតិវិធីក្នុងការទទួលបាននូវធានារ៉ាប់រងផ្នែកហានិភ័យការងារ

ដើម្បីទទួលបាននូវកិច្ចធានារ៉ាប់រងផ្នែកហានិភ័យការងារ (គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ និងជម្ងឺវិជ្ជាជីវៈ) ជំហានដំបូងនោះ គឺជនទាំងឡាយដែលស្ថិតក្រោមបញ្ញត្តិនៃច្បាប់ស្តីពីការងារ ឬកម្មករនិយោជិត ត្រូវក្លាយជាសមាជិកប.ស.ស. ជាមុនសិន ដោយនិយោជក ឬម្ចាស់សហគ្រាសត្រូវធ្វើការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតរបស់ខ្លួនជាមួយនឹងប.ស.ស.។ បន្ទាប់មក និយោជក ឬម្ចាស់សហគ្រាសនឹងជាប់កាតព្វកិច្ចធ្វើរបាយការណ៍ទាក់ទិនអំពីកម្មករនិយោជិត និងស្ថាប័នរបស់ខ្លួនផ្ទាល់ រួមទាំងកាតព្វកិច្ចបង់ភាគទានទៅតាមទម្រង់ និងនីតិវិធីដែលបានចែងក្រោមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងតាវកាលិកនៃផ្នែកហានិភ័យការងារ។ តាវកាលិកនៃផ្នែកហានិភ័យនឹងត្រូវផ្តល់ជូនចំពោះកម្មករនិយោជិតដែលជាសមាជិកប.ស.ស. នៅក្នុងពេលដែលជននេះទទួលរងគ្រោះថ្នាក់ដោយហានិភ័យការងារ ទៅតាមលទ្ធផល និងស្ថានភាពជាក់ស្តែងរបស់អ្នករងគ្រោះ ឬអ្នកជម្ងឺម្នាក់ៗ។ ដូច្នោះ ដើម្បីឈ្វេងយល់ និងដឹងឱ្យកាន់តែច្បាស់អំពីប្រព័ន្ធធានារ៉ាប់រងផ្នែកហានិភ័យការងារដែលអនុវត្តក្រោមដែនសមត្ថកិច្ចរបស់ប.ស.ស. ចំពោះបុគ្គលដែលស្ថិតក្រោមច្បាប់ស្តីពីការងារ ជំពូកទី២ នេះនឹងបកស្រាយបំភ្លឺនូវចំណុចសំខាន់ៗដូចជា៖ (២.១.) ការងារចុះបញ្ជិកាក្នុងប.ស.ស. (២.២.) ការបង់ភាគទានផ្នែកហានិភ័យការងារ និង (២.៣.) តាវកាលិកផ្នែកហានិភ័យការងារ។

## ២.១. ការងារចុះបញ្ជិកាក្នុងប.ស.ស.

ការងារចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងប.ស.ស. គឺជាកាតព្វកិច្ចរបស់និយោជកឬ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតក្រោមដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ ជាដំណាក់កាលចាប់ផ្តើមនៃការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ពោលត្រូវផ្នែកធានារ៉ាប់រងហានិភ័យការងារ ត្រូវអនុវត្តចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពី ០៨ នាក់ឡើង។[43] ដើម្បីធ្វើការចុះបញ្ជិកានេះ និយោជក ឬម្ចាស់សហគ្រាស ត្រូវអនុវត្តទៅតាមនីតិវិធី និងបែបបទដែលមានចែងក្នុងប្រកាសលេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដូចខាងក្រោម។

[43] ប្រកាស ០២២/០៨ កប-ប្រក ស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ, ប្រការ ២។

### ២.១.១. ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

#### ២.១.១.១. រយៈពេលនៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបើកដំណើរការថ្មីក្រោយពីប្រកាសខាងលើចូលជាធរមាន ត្រូវមានចុះបញ្ជិកានៅប.ស.ស. រយៈពេលយ៉ាងយូរ៣០ថ្ងៃ បន្ទាប់ពីការចាប់ផ្ដើមបើកសហគ្រាស គ្រឹះស្ថានជាស្ថាពរ។ ក្នុងករណីសហគ្រាស គ្រឹះស្ថាន កំពុងតែដំណើរការ និងមិនទាន់បានចុះបញ្ជិកានៅប.ស.ស. នឹងតម្រូវឱ្យមកចុះបញ្ជិការយៈពេលយ៉ាងយូរ ៣០ថ្ងៃ បន្ទាប់ពីប្រកាសលេខ ៤៤៨ ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមចូលជាធរមាន។[44] ដូចគ្នានេះដែរ ក្នុងករណីដែលមានការព្យួរ បិទ ឬផ្អាកសកម្មភាពអាជីវកម្ម ឬក្នុងករណីមានការប្ដូរនិយោជក ឬម្ចាស់សហគ្រាស ឬអ្នកតំណាង ឬអាសយដ្ឋាន ឬនាមករណ៍របស់សហគ្រាស និយោជក ឬម្ចាស់សហគ្រាសត្រូវជូនដំណឹងមក ប.ស.ស. ក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីករណីណាមួយខាងលើបានកើតឡើង។[45]

#### ២.១.១.២. លក្ខខណ្ឌទម្រង់នៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ចាំបាច់ត្រូវធ្វើការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ដោយបំពេញទៅតាមទម្រង់ «បញ្ជិកាសហគ្រាស គ្រឹះស្ថាន» ឬ ហៅម្យ៉ាងទៀតថាទម្រង់ «១.០១» ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធ១នៃប្រកាសលេខ ៤៤៨ ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដោយតម្រូវឱ្យភ្ជាប់មកជាមួយនូវវិញ្ញាបនបត្របញ្ជិកាពាណិជ្ជកម្ម ដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬលិខិតតួបករណ៍គតិយុត្តសមមូលដទៃទៀត។[46]

### ២.១.២. ការចុះបញ្ជិកាកម្មករនិយោជិត

#### ២.១.២.១. បែបបទក្នុងការចុះបញ្ជិកាកម្មករនិយោជិត

បែបបទក្នុងការចុះបញ្ជិកាកម្មករនិយោជិតនេះត្រូវបានប្រកាសលេខ ៤៤៨ ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម ចែកចេញជា ២ របៀបសម្រាប់ឱ្យនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន អនុវត្តតាមក្នុងករណីដែលសហគ្រាស គ្រឹះស្ថានរបស់ខ្លួនបានចុះបញ្ជិកានៅប.ស.ស.រួច តែពុំទាន់ចុះបញ្ជិកាសម្រាប់កម្មករនិយោជិត ឬក្នុងករណីដែលសហគ្រាស គ្រឹះស្ថានរបស់ខ្លួនពុំទាន់ចុះបញ្ជិកាណាមួយនៅឡើយ ពោលគឺការចុះបញ្ជិកាថ្មី។

##### ក. ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅប.ស.ស.

[44] ប្រកាសលេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង ប.ស.ស. ២០១៧, ប្រការ ៥។

[45] ប្រកាសលេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង ប.ស.ស. ២០១៧, ប្រការ ៦។

[46] ប្រកាសលេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង ប.ស.ស. ២០១៧, ប្រការ ៦។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវធ្វើការចុះបញ្ជិកា និងបំពេញព័ត៌មានឲ្យបានត្រឹមត្រូវទៅតាមទម្រង់ «សលាប័ត្រព័ត៌មានកម្មករនិយោជិត» ឬហៅម្យ៉ាងទៀតថាទម្រង់ «១.០២» ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធ២ នៃប្រកាសលេខ ៤៤៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនចំពោះកម្មករនិយោជិតបរទេស។ ប.ស.ស. នឹងផ្តល់កាលបរិច្ឆេទសម្រាប់ការចុះកំណត់អត្តសញ្ញាណសមាជិក ប.ស.ស. ទៅតាមមូលដ្ឋានសហគ្រាស គ្រឹះស្ថាន ព្រមទាំងលេខអត្តសញ្ញាណ និងប័ណ្ណសមាជិក ប.ស.ស. (ដោយឥតគិតថ្លៃ) ជូនទៅកម្មករនិយោជិតតាមរយៈនិយោជក ឬតំណាងនិយោជក។[47]

លើសពីនេះ ចំពោះកម្មករនិយោជិតដែលទើបចូលបម្រើការការងារថ្មី និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវចុះបញ្ជីកម្មករនិយោជិតនេះមក ប.ស.ស. យ៉ាងយូរ៣ថ្ងៃ បន្ទាប់ពីថ្ងៃអនុញ្ញាតឱ្យចូលបម្រើការ លើកលែងតែកម្មករនិយោជិតនោះមានប័ណ្ណសមាជិកប.ស.ស. រួចហើយ។[48]

### ខ. ចំពោះសហគ្រាស គ្រឹះស្ថាន ដែលចុះបញ្ជិកាថ្មី

ការចុះបញ្ជិកាកម្មករនិយោជិត ត្រូវចុះដំណាលគ្នានឹងការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន។ ក្នុងករណីសហគ្រាស គ្រឹះស្ថានមានកម្មករនិយោជិតចាប់ពី១០០នាក់ឡើង ប.ស.ស.នឹងផ្តល់កាលបរិច្ឆេទចុះទៅកំណត់អត្តសញ្ញាណកម្មករនិយោជិត។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវអនុវត្តកាតព្វកិច្ចក្នុងការបំពេញព័ត៌មានកម្មករនិយោជិតក្នុង «សលាប័ត្រព័ត៌មានកម្មករនិយោជិត» ឬទម្រង់ «១.០២» និងផ្តល់ឯកសារភ្ជាប់ដូចជាអត្តសញ្ញាណប័ណ្ណសញ្ញាណខ្មែរ ឬលិខិតឆ្លងដែនចំពោះកម្មករនិយោជិតបរទេស។[49]

ប្រសិនបើសហគ្រាស គ្រឹះស្ថាន មានកម្មករនិយោជិតក្រោម៥០នាក់ ប.ស.ស.នឹងផ្តល់កាលបរិច្ឆេទ ហើយនឹងអញ្ជើញនិយោជក ឬតំណាង និងកម្មករនិយោជិត មកកំណត់អត្តសញ្ញាណកម្មករនិយោជិតនៅប.ស.ស. ដោយត្រូវយកមកជាមួយនូវសលាប័ត្រព័ត៌មាន និងឯកសារភ្ជាប់ គឺប័ណ្ណសម្គាល់អត្តសញ្ញាណរបស់កម្មករនិយោជិតទាំងសញ្ជាតិខ្មែរ និងបរទេស។ បន្ទាប់មក ប.ស.ស. នឹងផ្តល់លេខអត្តសញ្ញាណ និងប័ណ្ណសមាជិក ប.ស.ស. ជូនកម្មករនិយោជិតតាមរយៈនិយោជក ឬតំណាង ដោយឥតគិតថ្លៃ។[50]

[47] ប្រកាសលេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង ប.ស.ស. ២០១៧, ប្រការ ៨។

[48] ប្រកាសលេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង ប.ស.ស. ២០១៧, ប្រការ ៧។

[49] បេឡាជាតិសន្តិសុខសង្គម. (២០១៤). ការងារចុះបញ្ជិកា, ដកស្រង់ចេញពី: www.nssf.gov.kh/ផ្នែកហានិភ័យការងារ/ការងារចុះបញ្ជិកា/, ថ្ងៃទី១៥ កក្កដា ឆ្នាំ២០២៣។

[50] បេឡាជាតិសន្តិសុខសង្គម. (២០១៤). ការងារចុះបញ្ជិកា, ដកស្រង់ចេញពី: www.nssf.gov.kh/ផ្នែកហានិភ័យការងារ/ការងារចុះបញ្ជិកា/, ថ្ងៃទី១៥ កក្កដា ឆ្នាំ២០២៣។

#### ២.១.២.២. ករណីខូច ឬបាត់បង់ប័ណ្ណសមាជិកប.ស.ស.

សាមីជនខ្លួនដែលជាម្ចាស់ប័ណ្ណត្រូវជូនដំណឹងទៅនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ហើយត្រូវស្នើសុំទុតិយតា ដែលជាសេចក្តីចម្លង ក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃបន្ទាប់ពីថ្ងៃជូនដំណឹង។ ការផ្តល់ប័ណ្ណទុតិយតានេះតម្រូវឱ្យសាមីខ្លួនបង់ប្រាក់ចំនួន ២ពាន់រៀលជូន ប.ស.ស.។[51]

#### ២.១.២.៣. របាយការណ៍ចំនួនកម្មករនិយោជិតក្រោយពីការចុះបញ្ជិការួច

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទៅ ប.ស.ស. យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់។ របាយការណ៍នេះត្រូវបញ្ជាក់អំពីចំនួនកម្មករនិយោជិតទាំងអស់ដែលមាននៅក្នុងខែត្រូវរាយការណ៍ និងត្រូវផ្តល់ជូនប.ស.ស. អាចក្រោយទម្រង់ជាក្រដាស ឬទម្រង់អេឡិចត្រូនិចដោយមានភ្ជាប់លិខិតបញ្ជូនចុះហត្ថលេខាដោយនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន។[52]

## ២.២. ការបង់ភាគទានផ្នែកហានិភ័យ

ក្រោយពីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន បានចុះបញ្ជិកាក្នុងប.ស.ស.រួច សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិត នឹងតម្រូវឱ្យបង់ភាគទានដែលជាប្រាក់ទុកជាមូលនិធិសម្រាប់ការផ្តល់តាវកាលិក ក្នុងការអនុវត្តកិច្ចធានារ៉ាប់រងដែលស្ថិតក្រោមសមត្ថកិច្ចអនុវត្តរបស់ប.ស.ស. មានកំណត់ក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម។ នៅក្នុងចំណុចនេះនឹងផ្តោតសំខាន់ទៅលើការបង់ភាគទានផ្នែកហានិភ័យការងារ។

### ២.២.១. ភាតព្វកិច្ច និងអត្រា

ការបង់ភាគទានផ្នែកហានិភ័យការងារ គឺជាកាតព្វកិច្ចដោយឡែករបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលត្រូវបង់ក្នុងអត្រា ០.៨ ភាគរយ(%)នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់ នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតមុនកាត់ពន្ធ ដោយប្រើប្រាស់ទម្រង់ «២.០១» ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសលេខ ៤៤៩ កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។[53] ប្រាក់ឈ្នួលជាមធ្យមជាប់ភាគទានខ្ពស់បំផុតគឺ ១.២០០.០០០រៀល និងមានទាំងអស់ ២២ថ្នាក់ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១ នៃប្រកាសលេខ ៤៤៩។

---

[51] ប្រកាសលេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង ប.ស.ស. ២០១៧, ប្រការ ១០។

[52] ប្រកាសលេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង ប.ស.ស.២០១៧, ប្រការ ១១។

[53] ប្រកាសលេខ ៤៤៩ ក.ប/ប្រ.ក.ប.ស.ស សស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកទាំងសុខភាពសម្រាបើជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ, ប្រការ ៤។

### ២.២.២. កាលបរិច្ឆេទ

ចំពោះការបង់ភាគទានដំបូង គឺត្រូវបានកំណត់ឱ្យបង់ក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលប.ស.ស. បានចេញនូវវិញ្ញាបនបត្រចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានជូន ហើយសម្រាប់ខែនីមួយៗបន្ទាប់មកទៀត និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់ភាគទានយ៉ាងយូរបំផុតនៅថ្ងៃទី១៥ នៃខែបន្ទាប់។ ក្នុងករណីខកខានមិន បានបង់ភាគទានតាមថ្ងៃកំណត់ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាននោះត្រូវបង់បន្ថែមនូវការប្រាក់ប្រចាំខែ ២ភាគរយ(%) នៃចំនួនភាគទានជាក់ស្តែងដែលត្រូវបង់តាមខែនីមួយៗ និងត្រូវបង់ប្រាក់ពិន័យពី១០ថ្ងៃ ទៅ ៣០ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ឬពី៣០ថ្ងៃ ទៅ ៩០ថ្ងៃនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃក្នុងករណីមិនរាងចាលស្រប តាមមាត្រា៣៦ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ ស្តីពីការងារ។[54]

### ២.២.៣. របៀបបង់ភាគទានផ្នែកហានិភ័យការងារ

ដើម្បីបង់ភាគទានផ្នែកហានិភ័យការងារជូនប.ស.ស. និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់ ទៅគណនីរបស់ប.ស.ស. ដែលស្ថិតក្នុងធនាគារ ACLEDA ដោយការទៅបង់ដល់ធនាគារផ្ទាល់ ឬបង់តាមរយៈ ACLEDA Unity ឬ Internet Banking។ បន្ទាប់មក និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវយកឯកសារ ដែលបានបង់ភាគទាននោះមកប.ស.ស. ដោយផ្ទាល់ ឬតាមរយៈសារអេឡិចត្រូនិចរួមទាំងភ្ជាប់ជាមួយនូវ ឯកសារមួយចំនួនដូចជា៖ បញ្ជិកាកម្មករនិយោជិត តារាងបើកបៀវត្ស លិខិតប្រកាសបង់ភាគទាន លិខិត បញ្ជាក់ពីនិយោជក និងបង្កាន់ដៃបង់ប្រាក់ពិន័យពីធនាគារ។[55] ប.ស.ស. នឹងចេញលិខិតបញ្ជាក់ការបង់ភាគ ទានជូនទៅនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានវិញ ក្រោយពីបានពិនិត្យឯកសារហើយឃើញថាត្រឹមត្រូវ។

## ២.៣. ដំណើរការនីតិវិធីក្នុងការទទួលបាននូវតាវកាលិកផ្នែកហានិភ័យការងារ

ហានិភ័យការងារដែលអាចកើតមានលើរូបកាយកម្មករនិយោជិតមាន៣ប្រភេទគឺ គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ និងជម្ងឺវិជ្ជាជីវៈ។ នៅពេលដែលហានិភ័យការងារប្រភេទណាមួយបានកើតមាន ចំពោះកម្មករនិយោជិតរបស់សហគ្រាស គ្រឹះស្ថាន ដែលបានធ្វើការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករ និយោជិតក្នុងប.ស.ស. ព្រមទាំងបានបំពេញកាតព្វកិច្ចបង់ភាគទានផ្នែកហានិភ័យការងារ មានសិទ្ធិទទួលបាន នូវតាវកាលិកពីប.ស.ស.។ គួរបញ្ជាក់ផងដែរថា សិទ្ធិទទួលបាននូវតាវកាលិកហានិភ័យការងារទាមទារឱ្យកម្មករ

[54] ប្រកាសលេខ២៩៤ ក.ប/ប្រក ស្តីពីការកែសម្រួលនៃប្រកាសលេខ ១០៨ កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការ បង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ, ប្រការ ៣ថ្មី។

[55] ប្រកាសលេខ២៩៤ ក.ប/ប្រក ស្តីពីការកែសម្រួលនៃប្រកាសលេខ ១០៨ កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការ បង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ, ប្រការ ៤ថ្មី។

និយោជិតព្រមនិយោជកអនុវត្តនូវកាតព្វកិច្ចចាំបាច់មួយចំនួនដូចខាងក្រោម ដើម្បីធានាប្រសិទ្ធិភាពក្នុងការអនុវត្តកិច្ចធានារ៉ាប់រងនៃរបបសន្តិសុខសង្គម។

### ២.៣.១. ការជូនដំណឹង និងការអង្កេតហានិភ័យការងារ

កម្មករនិយោជិតដែលជាសមាជិកនៃប.ស.ស. ត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬតំណាងនិយោជក អំពីហានិភ័យការងារដែលធ្លាក់មកលើខ្លួន។ ក្នុងករណីគ្រោះថ្នាក់បណ្តាលឱ្យបាត់បង់ជីវិត កាតព្វកិច្ចក្នុងការជូនដំណឹងនេះត្រូវធ្លាក់លើសិទ្ធិវន្តនៃជនរងគ្រោះដែលអាចជាប្រពន្ធ ឬប្តី ឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក ឬកូន។ បន្ទាប់ពីទទួលបានការជូនដំណឹងអំពីហានិភ័យការងារដែលកើតមានចំពោះកម្មករនិយោជិតរបស់ខ្លួន និយោជក ឬអ្នកតំណាងនិយោជកត្រូវជូនដំណឹងមកប.ស.ស. ក្នុងរយៈពេលយ៉ាងយូរបំផុត ៤៨ម៉ោងនៃថ្ងៃធ្វើការក្រោមទម្រង់ «របាយការណ៍ហានិភ័យការងារ» ដែលព័ត៌មានត្រូវរាយការណ៍ជាចាំបាច់រួមមាន៖[56]

- **ព័ត៌មានអំពីសហគ្រាស៖** នាមករណ៍ លេខអត្តសញ្ញាណសហគ្រាស អាសយដ្ឋានសហគ្រាស លេខទូរស័ព្ទ លេខទូរសារ E-mail address។
- **ព័ត៌មានអំពីកម្មករនិយោជិត៖** ឈ្មោះពេញរបស់កម្មករនិយោជិត លេខអត្តសញ្ញាណកម្មករនិយោជិត អាសយដ្ឋានអចិន្ត្រៃយ៍ លេខទូរស័ព្ទ លេខទូរសារ E-mail address។
- **ព័ត៌មានលំអិតគ្រោះថ្នាក់ការងារ៖** បញ្ជាក់ពីប្រភេទគ្រោះថ្នាក់ កាលបរិច្ឆេទគ្រោះថ្នាក់ ម៉ោងគ្រោះថ្នាក់ ទីកន្លែងគ្រោះថ្នាក់ មូលហេតុគ្រោះថ្នាក់ សាក្សី ឈ្មោះមន្ទីរពេទ្យ ឬគ្លីនិកសំរាកព្យាបាល និងព័ត៌មានលំអិតស្តីពីប្រាក់ឈ្នួល ៦ខែចុងក្រោយរបស់កម្មករដែលរងគ្រោះថ្នាក់ ឬក៏របស់កម្មករដែលមានគុណវឌ្ឍដូចគ្នានឹងកម្មករដែលរងគ្រោះថ្នាក់។

បន្ទាប់ពីទទួលបានរបាយការណ៍ហានិភ័យការងារ ការិយាល័យតាវកាលិក ដែលជាការិយាល័យចំណុះក្រោមសាខាប.ស.ស. ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវជូនដំណឹងទៅការិយាល័យអធិការកិច្ច ដែលជាការិយាល័យចំណុះក្រោមនាយកដ្ឋានអធិការកិច្ចសន្តិសុខសង្គម ដើម្បីធ្វើការអង្កេតនឹងផ្តល់លទ្ធផលលើករណីគ្រោះថ្នាក់នីមួយៗមកការិយាល័យតាវកាលិកវិញឱ្យបានយ៉ាងឆាប់បំផុត ថាតើគ្រោះថ្នាក់នេះ ជាគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ការងារក្នុងពេលធ្វើដំណើរ ឬជម្ងឺវិជ្ជាជីវៈ ឬមិនមែន នេះក៏ព្រោះតែមិនមែនគ្រោះថ្នាក់ទាំងអស់ដែលកើតមានចំពោះកម្មករនិយោជិតជាសមាជិកប.ស.ស.សុទ្ធសឹងតែជាហានិភ័យការងារនោះទេ។[57]

---

[56] ប្រកាសលេខ១១០ កប/ប្រ.ក ស្តីពីការជូនដំណឹងហានិភ័យការងារ, ប្រការ ១។

[57] បេឡាជាតិសន្តិសុខសង្គម. (២០១៤). តាវកាលិក, ដកស្រង់ចេញពី: www.nssf.gov.kh/ផ្នែកហានិភ័យការងារ/តាវកាលិក/, ថ្ងៃទី១៥ កក្កដា ឆ្នាំ២០២៣។

### ២.៣.២. តាវកាលិកផ្នែកហានិភ័យការងារ

ប្រសិនបើលទ្ធផលនៃការអង្កេតពីការិយាល័យអធិការកិច្ចបង្ហាញថាគ្រោះថ្នាក់ដែលកើតមានចំពោះកម្មករនិយោជិតពិតជាហានិភ័យការងារ នោះកម្មករនិយោជិតដែលជាអ្នករងគ្រោះ មានសិទ្ធិទទួលបាននូវតាវកាលិកពីប.ស.ស.។ តាវកាលិកនឹងត្រូវបានផ្តល់ទៅតាមស្ថានភាព និងកាលៈទេសៈរបស់អ្នករងគ្រោះ។

#### ២.៣.២.១.សេវាថែទាំវេជ្ជសាស្ត្រ ព្យាបាល និងសង្គ្រោះបន្ទាន់

កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ មានសិទ្ធិទទួលបានការពិនិត្យព្យាបាល និងការសម្រាលព្យាបាលនៅតាមបណ្តាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយប.ស.ស. ដូចខាងក្រោម៖[58]

- ការព្យាបាល និងថែទាំមុខរបួស ឬជម្ងឺដែលបណ្តាលមកពីហានិភ័យការងារតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ រហូតដល់ជាសះស្បើយទោះអ្នករងគ្រោះសម្រាក ឬមិនសម្រាកព្យាបាលទៅតាមមូលដ្ឋានសុខាភិបាលក្តី
- ការផ្តល់សេវាសង្គ្រោះបន្ទាន់ចំពោះគ្រោះថ្នាក់ដែលកើតឡើងនៅកន្លែងធ្វើការ និយោជកត្រូវផ្តល់ការសង្គ្រោះបន្ទាន់នៅជិតបំផុត និងត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលប.ស.ស. ទទួលស្គាល់ ដោយការចំណាយនេះជាបន្ទុករបស់ប.ស.ស.។ ក្នុងករណីគ្រោះថ្នាក់នៅពេលធ្វើដំណើរសាមីជន ឬនិយោជកអាចធ្វើការទាមទារការទូទាត់សងលើការចំណាយសម្រាប់ការសង្គ្រោះនេះពីប.ស.ស.។[59]
- ការផ្គត់ផ្គង់ឱសថសម្រាប់ការព្យាបាល និងសម្ភារៈប្រើប្រាស់បន្ទាប់បន្សំសម្រាបការព្យាបាល
- ការផ្តល់សេវាដឹកសព ឬសេវាបញ្ជូនជនរងគ្រោះដែលត្រូវសង្គ្រោះបន្ទាន់
- ការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំ ក្នុងពេលសម្រាកព្យាបាលសម្រាប់ករណីធ្ងន់ធ្ងរដែលសាមីជនដែលរងគ្រោះមិនអាចបម្រើខ្លួនឯងបាន។

ក្នុងករណីដែលគ្រូពេទ្យព្យាបាលតម្រូវឱ្យទិញឱសថ ឬសម្ភារៈឧបករណ៍ដែលចាំបាច់សម្រាប់ការថែទាំ និងព្យាបាលដែលពុំមានចែងនៅក្នុងកិច្ចព្រមព្រៀងជាមួយប.ស.ស. ការចំណាយនេះអាចទូទាត់សងទៅជនរងគ្រោះ ឬអ្នកតំណាងវិញបានលុះត្រាណាតែមានវេជ្ជបញ្ជា និងវិក្កយបត្របញ្ជាក់ត្រឹមត្រូវ។[60]

[58] ច្បាប់ស្តីពីរបបសន្តិសុខសង្គម ២០១៩, មាត្រា ៦៩, ៧៥។

[59] បេឡាជាតិសន្តិសុខសង្គម. (២០១៤). តាវកាលិក, ដកស្រង់ចេញពី: www.nssf.gov.kh/ផ្នែកហានិភ័យការងារ/តាវកាលិក/, ថ្ងៃទី១៥ កក្កដា ឆ្នាំ២០២៣។

[60] ប្រកាសលេខ១០៩ កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ២០០៨, ប្រការ ៥។

### ២.៣.២.២. តាវកាលិកបាត់បង់សមត្ថភាពការងារ

#### ក. តាវកាលិកបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្ន

ក្នុងរយៈពេលនៃការសម្រាកព្យាបាលមុខរបួស ឬជម្ងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល និងរយៈពេលនៃការសម្រាកក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជាសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្ន កម្មករនិយោជិតដែលរងគ្រោះមានសិទ្ធិទទួលបានតាវកាលិកពីប.ស.ស. ពោលគឺប្រាក់បំណាច់ប្រចាំថ្ងៃ ដែលត្រូវផ្ដល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការកើតឧបទ្ទវហេតុ និងតម្រូវឱ្យមានការសម្រាកព្យាបាលលើសពី០៤ថ្ងៃឡើងទៅ។[61] ចំណែកឯ បន្ទុកចំណាយក្នុងថ្ងៃជួបគ្រោះថ្នាក់គឺជាបន្ទុករបស់និយោជក។ រូបមន្តសម្រាប់គណនាប្រាក់បំណាច់ប្រចាំថ្ងៃ៖

**ប្រាក់បំណាច់ប្រចាំថ្ងៃ** = ៧០ភាគរយ(%) នៃប្រាក់ឈ្នួលមធ្យមចែកនឹង៣០

ដោយប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃស្មើនឹងប្រាក់ឈ្នួលមធ្យមចែកនឹង៣០ ហើយប្រាក់ឈ្នួលមធ្យមស្មើនឹងប្រាក់ឈ្នួលជាប់ភាគទានបូកចូលគ្នា(ដែលមិនលើសពី៦ខែ) ចែកនឹងចំនួនខែ។ សិទ្ធិក្នុងការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃ ត្រូវអស់សុពលភាពត្រឹមរយៈពេល១ឆ្នាំ។[62] បន្ថែមពីនេះ ក្នុងករណីមានអ្នកថែទាំ ប.ស.ស.ក៏ផ្ដល់នូវប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំអ្នករងគ្រោះថ្នាក់ដោយប្រាក់ឧបត្ថម្ភនោះស្មើនឹង៥០ភាគរយ(%) នៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់អ្នករងគ្រោះ។[63]

#### ខ. តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

ក្នុងករណីដែលអ្នករងគ្រោះបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង ២០ភាគរយ(%) មានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ ដែលនឹងផ្ដល់ជូនតែម្ដងគត់។ ប្រាក់វិភាជន៍បាត់បង់សកម្មភាព ស្មើនឹងប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ គុណនឹងកម្រិតនៃសមត្ថភាពការងាររបស់ជនរងគ្រោះ គុណនឹង២០ភាគរយ(%) នៃមេគុណតម្លៃបច្ចុប្បន្ន។ រូបមន្ត វបក = បឈម x កបក x ២០%មតប។[64]

ក្នុងករណីដែលអ្នករងគ្រោះបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ចាប់ពី ២០ភាគរយ(%)ឡើង មានសិទ្ធិទទួលបាននូវធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ដែលការផ្ដល់ឱ្យនេះត្រូវស្ថិត

---

[61] ប្រកាសលេខ១៤០ កប/ប្រក ស្ដីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ស្ដីពីតាវកាលិកហានិភ័យការងារ, ប្រការ ៧ថ្មី។

[62] ប្រកាសលេខ៤៨០ កប/ប្រក ស្ដីពីការកែសម្រួលប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ១០៩ កប/ប្រក ស្ដីពីតាវកាលិកហានិភ័យការងារ ២០១៨, ប្រការ ៦ថ្មី និងប្រការ ១៣ថ្មី។

[63] ប្រកាសលេខ១៤០ កប/ប្រក ស្ដីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ស្ដីពីតាវកាលិកហានិភ័យការងារ, ប្រការ ៩ថ្មី។

[64] ប្រកាសលេខ២៣៣ ស្ដីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ស្ដីពីតាវកាលិកហានិភ័យការងារ, ប្រការ ៨ថ្មី។

ក្រោមការពិនិត្យសុខាភាពឡើងវិញជាទៀងរាល់ឆ្នាំ។ ធនលាភ ស្មើនឹងកម្រិតនៃសមត្ថភាពការងាររបស់ជនរងគ្រោះ ដកនឹងមួយភាគប្រាំនៃកម្រិតនៃសមត្ថភាពការងាររបស់ជនរងគ្រោះ គុណនឹងប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ។ រូបមន្ត ធល = បឈម x [កបក - ១/៥កបក]។[65] សិទ្ធិក្នុងការទាមទារប្រាក់ធនលាភត្រូវអស់សុពលភាពត្រឹមរយៈពេល៥ឆ្នាំ។

## តារាងកម្រិតនៃការបាត់បង់សមត្ថភាព[66]

### ផ្នែកទី១៖ បញ្ជីគ្រោះថ្នាក់ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ទាំងស្រុង

| ល.រ | ការបរិយាយអំពីគ្រោះថ្នាក់ | ភាគរយនៃការបាត់បង់សមត្ថភាពការងារ |
|---|---|---|
| ១ | បាត់បង់ប្រអប់ដៃទាំងពីរ ឬកាត់នៅផ្នែកខាងលើ | ១០០ |
| ២ | បាត់ប្រអប់ដៃមួយ និងប្រអប់ជើងមួយ | ១០០ |
| ៣ | កាត់ជើង ឬភ្លៅ ឬកាត់ជើង ឬភ្លៅម្ខាង និងបាត់ប្រអប់ជើងម្ខាងទៀត | ១០០ |
| ៤ | បាត់បង់ចក្ខុប្រសាទនៅកម្រិតណាមួយដែលមិនអាចឱ្យអ្នកទាមទារបំពេញការងារដែលប្រើប្រាស់ក្រសៃភ្នែកជាសំខាន់ | ១០០ |
| ៥ | ការខូចទ្រង់ទ្រាយមុខធ្ងន់ធ្ងរ | ១០០ |
| ៦ | ថ្លង់ទាំងស្រុង | ១០០ |

### ផ្នែកទី២៖ បញ្ជីគ្រោះថ្នាក់ដែលបណ្តាលឱ្យបាត់បងសមត្ថភាពការងារអនិច្ចៃយ៍

| ល.រ | ការបរិយាយអំពីគ្រោះថ្នាក់ | ភាគរយនៃការបាត់បង់សមត្ថភាពការងារ |
|---|---|---|
| **ការកាត់អវៈយវៈផ្នែកខាងលើ (ដៃមួយណាក៏បាន)** | | |
| ១ | កាត់សន្លាក់ស្មា | ៩០ |
| ២ | កាត់ក្រោមស្មាដែលគល់នៅតិចជាង៨″ ពីចុងនៃ acromion | ៨០ |

[65] ប្រកាសលេខ២៣៣ ស្តីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ២០០៨, ប្រការ ៨ថ្មី។

[66] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យ ២០០៨, ឧបសម្ព័ន្ធ ២។

| | | |
|---|---|---|
| ៣ | កាត់៨″ ពីចុងនៃ Acromion ទៅតិចជាង ៤″ ក្រោមចុងនៃ olecranon | ៧០ |
| ៤ | បាត់ប្រអប់ដៃ ឬមេដៃ និងម្រាម៤ នៃប្រអប់ដៃមួយ ឬកាត់ពី៤ ១/២ ″ក្រោមចុងនៃ olecranon | ៦០ |
| ៥ | បាត់មេដៃ | ៣០ |
| ៦ | បាត់មេដៃ និងឆ្អឹង metacarpal | ៤០ |
| ៧ | បាត់ម្រាមបួននៃប្រអប់ដៃមួយ | ៥០ |
| ៨ | បាត់ម្រាមបីនៃប្រអប់ដៃមួយ | ៣០ |
| ៩ | បាត់ម្រាមពីរនៃប្រអប់ដៃមួយ | ២០ |
| ១០ | បាត់ថ្នាំងចុងក្រោយនៃមេដៃ | ២០ |
| **ការកាត់អវៈយវៈផ្នែកខាងក្រោម** | | |
| ១១ | កាត់ប្រអប់ជើងទាំងពីរបណ្តាលឱ្យដើរខិច | ៩០ |
| ១២ | កាត់តាម feet proximal ទាំងពីរទៅ Metatarso-phalangeal joint | ៨០ |
| ១៣ | បាត់ម្រាមជើងទាំងអស់នៃប្រអប់ជើងទាំងពីរតាម Metatarso-phalangeal joint | ៤០ |
| ១៤ | បាត់ម្រាមជើងទាំងអស់នៃ Feet proximal ទាំងពីរទៅ Proximal inter-phalangeal joint | ៣០ |
| ១៥ | បាត់ម្រាមជើងទាំងអស់នៃ Feet distal ទាំងពីរទៅ Proximal inter-phalangeal joint | ២០ |
| ១៦ | កាត់ត្រគាក | ៩០ |
| ១៧ | កាត់ក្រោមត្រគាកដែលសល់គល់ប្រវែងមិនលើស5″ ដែលវាស់ពីចុងនៃ Great Trochanter | ៨០ |
| ១៨ | កាត់ក្រោមត្រគាកដែលសល់គល់ប្រវែងមិនលើស5″ ដែលវាស់ពីចុងនៃ Great Trochanter ប៉ុន្តែមិនហួសពីពាក់កណ្តាលភ្លៅ | ៧០ |

| | | |
|---|---|---|
| ១៩ | កាត់ក្រោមពាក់កណ្ដាលភ្លៅទៅ3˝ /z˝ ក្រោមជង្គង់ | ៦០ |
| ២០ | កាត់ក្រោមជង្គង់ដែលនៅសល់គល់លើស 3˝/2˝ ប៉ុន្តែមិនលើស5˝ | ៥០ |
| ២១ | កាត់ក្រោមជង្គង់ដោយសល់គល់លើសពី 5˝ | ៤០ |
| ២២ | កាត់ប្រអប់ជើងមួយបណ្ដាលឱ្យដើរទប់ខាងចុង | ៣០ |
| ២៣ | កាត់ពី Foot proximal មួយទៅ Meta torso phalangeal joint | ៣០ |
| ២៤ | បាត់ម្រាមជើងទាំងអស់នៃប្រអប់ជើងមួយតាម Meta torso phalangeal joint | ២០ |
| ២៥ | បាត់ភ្នែកម្ខាងដោយគ្មានភាពស្មុគស្មាញ ហើយម្ខាងទៀតនៅធម្មតា | ៤០ |
| ២៦ | បាត់ចក្ខុវិញ្ញាណនៃភ្នែកម្ខាងដោយគ្មានភាពស្មុគស្មាញ ឬដោយគ្មានការខូចទ្រង់ទ្រាយនៃគ្រាប់ភ្នែក ហើយម្ខាងទៀតនៅធម្មតា | ៣០ |
| ២៧ | ត្រចៀកម្ខាងថ្លង់ទាំងស្រុង | ២០ |
| **ក-ម្រាមដៃឆ្វេង ឬស្ដាំ** | | |
| **ចង្អុលដៃ** | | |
| ២៨ | ទាំងមូល | ១៤ |
| ២៩ | ពីរថ្នាំងដៃ | ១១ |
| ៣០ | មួយថ្នាំងដៃ | ៩ |
| ៣១ | កាត់ចុងដោយម៉ាស៊ីនដោយមិនបាត់ឆ្អឹង | ៥ |
| **ម្រាមកណ្ដាល** | | |
| ៣២ | ទាំងមូល | ១២ |
| ៣៣ | ពីរថ្នាំងដៃ | ៩ |
| ៣៤ | មួយថ្នាំងដៃ | ៧ |
| ៣៥ | កាត់ចុងដោយម៉ាស៊ីនដោយមិនបាត់ឆ្អឹង | ៤ |

| | | |
|---|---|---|
| **នាងដៃ និងកូនដៃ** | | |
| ៣៦ | ទាំងមូល | ៧ |
| ៣៧ | ពីរថ្នាំងដៃ | ៦ |
| ៣៨ | មួយថ្នាំងដៃ | ៥ |
| ៣៩ | កាត់ចុងដោយម៉ាស៊ីនដោយមិនបាត់ឆ្អឹង | ២ |
| **ខ-ម្រាមជើងឆ្វេង ឬស្តាំ** | | |
| **មេជើង** | | |
| ៤០ | Through metatarso-phalangeal joint | ១៤ |
| ៤១ | Part, with some loss of bone | ៣ |
| **ម្រាមជើងដទៃទៀត** | | |
| ៤២ | Through metatarso-phalangeal joint | ៣ |
| ៤៣ | Part, with some loss of bone | ១ |
| **ម្រាមពីរនៃប្រអប់ជើងមួយ មិនគិតមេជើង** | | |
| ៤៤ | Through metatarso-phalangeal joint | ៥ |
| ៤៥ | Part, with some loss of bone | ២ |
| **ម្រាមបីនៃប្រអប់ជើងមួយ មិនគិតមេជើង** | | |
| ៤៦ | Through metatarso-phalangeal joint | ៦ |
| ៤៧ | Part, with some loss of bone | ៣ |
| **ម្រាមបួននៃប្រអប់ជើងមួយ មិនគិតមេជើង** | | |
| ៤៨ | Through metatarso-phalangeal joint | ៩ |
| ៤៩ | Part, with some loss of bone | ៣ |

### ២.៣.២.៣. ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព

ករណីចុងក្រោយ គឺករណីបាត់បង់ជីវិតដោយសារហានិភ័យការងារ អ្នកទទួលបន្ទុករ៉ាប់រងក្នុងការចាត់ចែងបូជាសពនឹងទទួលបានប្រាក់វិភាជន៍ជាសោហ៊ុយបូជាសពចំនួន ៤លានរៀល។[67] សិទ្ធិក្នុងការទាមទារប្រាក់វិភាជន៍បូជាសព ត្រូវអស់សុពលភាពក្នុងរយៈពេល១ឆ្នាំ។[68]

### ២.៣.២.៤. តាវកាលិកឧត្តរជីវី

តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្តល់ឱ្យសិទ្ធិវន្តនៃជនគ្រោះដែលបានទទួលរងនូវហានិភ័យការងារ។ សិទ្ធិវន្តត្រូវតែជា៖[69]

- ប្រពន្ធ ឬប្តីនៃជនរងគ្រោះ ដែលមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ចុះមុនកាលបរិច្ឆេទនៃហានិភ័យការងារ ឬមុនពេលទទួលមរណភាពដោយហានិភ័យការងារ។
- ចំពោះកូន ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖
  - មិនទាន់រៀបអាពាហ៍ពិពាហ៍
  - កូននៃសហព័ន្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវ។ ក្នុងករណីមានការលែងលះ ឬមរណភាពនៃប្តី ឬប្រពន្ធ នោះកូននៃអាពាហ៍ពិពាហ៍ក្រោយក៏មានសិទ្ធិដូចកូនអាពាហ៍ពិពាហ៍ទី១ដែរ
  - ជាកូនបង្កើត ឬកូនចិញ្ចឹម ដែលបានសុំតាមបទប្បញ្ញត្តិជាធរមាន ឬក្មេងកំពាររស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ
  - មានអាយុមិនលើសពី២១ឆ្នាំ ដោយកូនក្នុងបន្ទុកអាចកំណត់ដល់២១ឆ្នាំនេះគឺអនុវត្តចំពោះកូនដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬកូនកំពុងរៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឬឯកជនដែលមានការទទួលស្គាល់លើពីស្ថាប័នមានសមត្ថកិច្ច និងមានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ
  - កូនពិការ ឬមានជម្ងឺរ៉ាំរ៉ៃមិនមានលទ្ធភាពធ្វើការងារដែលមានប្រាក់ចំណូលត្រូវផ្តល់ធនលាភឧត្តរជីវីអស់មួយជីវិត ដោយការកំណត់ស្ថានភាពពិការ ឬជម្ងឺរ៉ាំរ៉ៃនេះតម្រូវមានការបញ្ជាក់ដោយគ្រូពេទ្យឯកទេស និងមានការយល់ព្រមពីក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស.។

---

[67] ប្រកាសលេខ២៣៣ ស្តីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ២០០៨, ប្រការ ១០ថ្មី។

[68] ប្រកាសលេខ៤៨០ កប/ក្រប ស្តីពីការកែសម្រួលប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ២០១៨, ប្រការ ១៣ថ្មី។

[69] ច្បាប់ស្តីពីរបបសន្តិសុខសង្គម ២០១៩, មាត្រា ៦៨។

- ឪពុកម្តាយ ឬមនុស្សចាស់ជរាដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់សមាជិកប.ស.ស. ដែលមានអាយុយ៉ាងតិច៦០ឆ្នាំ គិតត្រឹមថ្ងៃនៃការទទួលមរណភាពរបស់ជនរងគ្រោះ និងមិនមានប្រកបមុខរបរដែលមានប្រាក់ចំណូល ឬប្រាក់សោធនវិត្តន៍ ឬសោធនជរាភាព។ ការកំណត់អាយុនេះ ពុំត្រូវបានយកមកអនុវត្តចំពោះឪពុកម្តាយ ឬមនុស្សចាស់ជរាដែលមានជម្ងឺរ៉ាំរ៉ៃព្យាបាលមិនជា ឬមានទុព្វលភាព និងមិនមានប្រាក់ចំណូល ឬប្រាក់សោធនវិត្តន៍ ឬសោធនជរាភាព។

តាវកាលិកឧត្តមជីវី នឹងគិតតាមអត្រាដូចខាងក្រោម៖[70]

ក. ករណីសិទ្ធិវន្តមានទាំងប្រពន្ធ ឬប្តី កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក

- ប្រពន្ធ ឬប្តី = ៣/៥ x ៦៣% បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៦៣%បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក= ៧% បឈម

ខ. ករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្តី និង/ឬកូន

- ប្រពន្ធ ឬប្តី = ៣/៥ x ៧០% បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៧០% បឈម

គ. ករណីសិទ្ធិវន្តមានតែឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក=២៨% បឈម

ឃ. ករណីសិទ្ធិវន្តមានតែកូន និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក=២៨% បឈម

ង. ករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្តី និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ប្រពន្ធ ឬប្តី = ២៨% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក=២៨% បឈម

សិទ្ធិទទួលបានធនលាភនៃសិទ្ធិវន្ត ត្រូវបានរំលាយនៅពេលដែលសាមីជនទទួលមរណភាព។ ចំពោះសហព័ន្ធ សិទ្ធិទទួលបានធនលាភនៃសិទ្ធិវន្តនឹងរលត់នៅពេលដែលសហព័ន្ធនោះរៀបអាពាហ៍ពិពាហ៍ថ្មី។ ក្នុង

[70] ប្រកាសលេខ៤៨០ ក.ប/ប្រ.ក.ប.ស.ស ស្តីពីការកែសម្រួលប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ១០៩ កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ២០១៨, ប្រការ១១ថ្មី។

ករណីដែលសហព័ន្ធនោះរៀបអាពាហ៍ពិពាហ៍ថ្មី សាមីជនត្រូវជូនដំណឹងមក ប.ស.ស. យ៉ាងយូរ ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍ថ្មីនេះ។[71]

### ២.៣.២.៤. សេវាស្តារនីតិសម្បទា

កម្មករនិយោជិតដែលទទួលរងគ្រោះដោយហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍មានសិទ្ធិទទួលបាននូវឧបករណ៍ ឬ អវៈយវៈសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យដែលទទួលស្គាល់ដោយ ប.ស.ស.។[72] លើសពីនេះទៅទៀត អ្នករងគ្រោះក៏ទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ស្របតាមលក្ខខណ្ឌ ដែលនឹងកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពោលគឺប្រកាសលេខ ៤៧៧ ក.ប/ប្រ.ក.ប.ស.ស ស្តីពីសេវាស្តារនីតិសម្បទា សម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ (ប្រកាសលេខ ៤៧៧)។

ការស្នើសុំសេវាស្តារនីតិសម្បទា ត្រូវធ្វើឡើងតាមទម្រង់ «ពាក្យស្នើសុំសេវាស្តារនីតិសម្បទា» ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសលេខ ៤៧៧ ដែលតម្រូវឱ្យភ្ជាប់ជាមួយនូវវេជ្ជបញ្ជារបស់គ្រូពេទ្យ ឬអ្នកឯកទេសដែលទទួលស្គាល់ដោយ ប.ស.ស. ឬឯកសារពាក់ព័ន្ធចាំបាច់ដទៃទៀត។ សេវានេះ ត្រូវបានទទួលការយល់ពីបេឡាជាតិរបបសន្តិសុខសង្គម លុះត្រាតែធ្វើឡើងដោយមានការអនុញ្ញាតនៅក្នុងមជ្ឈមណ្ឌល ឬអង្គភាពផ្តល់សេវាស្តារនីតិសម្បទា ដែលកំណត់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ ការផ្តល់សេវាស្តារនីតិសម្បទា ឬការចំណាយដែលពាក់ព័ន្ធនឹងការផ្តល់សេវា គឺជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។[73]

ការស្នើសុំសេវាស្តារនីតិសម្បទាចំពោះជនពិការ គឺជាតម្រូវឱ្យជននោះមកបង្ហាញខ្លួននៅបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីពិនិត្យ វាយតម្លៃ និងតម្រង់ទិសការផ្តល់សេវា។ ប្រសិនបើជនពិការមិនអាចបង្ហាញខ្លួនក្នុងការស្នើសុំដោយសារស្ថានភាពពិការមានសភាពធ្ងន់ធ្ងរ ការស្នើសុំនេះអាចធ្វើឡើងដោយអ្នកតំណាង ដែលអាចជាសហព័ន្ធ កូន ឬជនដែលមានភារៈថែរក្សាដោយផ្ទាល់ចំពោះជនពិការ។ បន្ថែមពីនេះទៀតនេះ ជនពិការត្រូវមានភាពសមស្របនូវលក្ខខណ្ឌកាយសម្បទា សតិបញ្ញា កត្តាជំរុញ ឬសមត្ថភាពដែលអាចជំរុញបាន ព្រម

---

[71] ប្រកាសលេខ១០៩ កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ២០០៨, ប្រការ១១។

[72] ច្បាប់របបសន្តិសុខសង្គម ២០១៩, មាត្រា៦៨; ប្រកាសលេខ១០៩ កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ២០០៨, ប្រការ១២។

[73] ប្រកាសលេខ ៤៧៧ ក.ប/ប្រ.ក.ប.ស.ស ស្តីពីសេវាស្តារនីតិសម្បទា សម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ២០១៨, ប្រការ ៥, ៦, ៧។

ទាំងឆន្ទៈសហការជាមួយអ្នកផ្តល់សេវា ដើម្បីទទួលយកបាននូវការផ្តល់សេវាស្តារនីតិសម្បទា។ ការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញនេះ ត្រូវបានផ្តល់ជូនរយៈពេលយ៉ាងយូរ១ឆ្នាំ។[74]

**២.៣.២.៥. ជម្ងឺរ៉ាំរ៉ៃ**

ប្រភេទជម្ងឺដែលត្រូវបានកំណត់ថាជាជម្ងឺរ៉ាំរ៉ៃក្រោមប្រកាសលេខ ២៣៨ ក.ប/ប្រ.ក ស្តីពីការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព មានដូចខាងក្រោម៖[75]

១. ជំងឺខ្សោយបេះដូង

២. ជំងឺសាច់ដុំបេះដូង

៣. ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ

៤. ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ

៥. ជំងឺតំរងនោមរ៉ាំរ៉ៃ

៦. ជំងឺក្រិនថ្លើម

៧. ជំងឺសរសៃឈាមក្រហមបេះដូង

៨. ជំងឺទឹកនោមផ្អែមប្រភេទទី១ និងទី២

៩. ជំងឺវិបត្តិចង្វាក់បេះដូង

១០. ជំងឺក្រិនសរីរាង្គ

១១. ជំងឺវិកលចរិត

១២. ជំងឺលុយពុស

១៣. ជំងឺលើសឈាម

១៤. ជំងឺតាឡាសសីមី។

[74] ប្រកាសលេខ ៤៧៧ ក.ប/ប្រ.ក.ប.ស.ស ស្តីពីសេវាស្តារនីតិសម្បទា សម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ២០១៨, ប្រការ ៥, ៦, ១០។

[75] ប្រកាសលេខ ២៣៨ ក.ប/ប្រ.ក ស្តីពីការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ២០១៦, ប្រការ ២។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សា និងស្រាវជ្រាវជុំវិញប្រធានបទ **«ការធានារ៉ាប់រងហានិភ័យការងារចំពោះបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ការងារ»** នេះរួចមក បានបង្ហាញឱ្យឃើញថាការធានារ៉ាប់រងចំពោះផ្នែកហានិភ័យការងារចំពោះបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ការងារ ត្រូវបានអង្គការនីតិបញ្ញត្តិអនុម័តច្បាប់ជាច្រើន ក៏ដូចជាអនុក្រឹត្យ ក្នុងគោលបំណងអនុវត្តការធានារ៉ាប់រងចំពោះផ្នែកហានិភ័យការងារចំពោះបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ការងារនេះឱ្យបានរលូននៅក្នុងព្រះរាជណាចក្រកម្ពុជា។ ការធានារ៉ាប់រងចំពោះផ្នែកហានិភ័យការងារ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ដល់កម្មករនិយោជិតដែលបម្រើការងារនៅក្នុងវិស័យឯកជនក្នុងការទទួលបានការគាំពារសុខភាព ក៏ដូចជាទទួលតាវកាលិករួមមានការទទួលបានការព្យាបាលនៅពេលមានគ្រោះថ្នាក់ការងារ ឬជំងឺវិជ្ជាជីវៈដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ចំណែកឯនីតិវិធី និងបែបបទក្នុងទទួលបាននូវធានារ៉ាប់រងហានិភ័យការងារវិញមានភាពច្បាស់លាស់ដោយភ្ជាប់មកនូវទម្រង់ឯកសារ លក្ខខណ្ឌនិងព័ត៌មានជាក់លាក់ ក្នុងការចុះបញ្ជិកា ការបង់ភាគទាន។ ការស៊ើបអង្កេត ពិនិត្យ និងវិនិច្ឆ័យអំពីមូលហេតុនៃគ្រោះថ្នាក់ដែលកើតមានចំពោះកម្មករនិយោជិត នៅមុនពេលផ្ដល់តាវកាលិកផ្នែកហានិភ័យការងារ គឺដើម្បីធានាប្រសិទ្ធិភាព និងភាពប្រាកដប្រាជាក្នុងការអនុវត្តច្បាប់ស្ដីពីរបបសន្ដិសុខសង្គម។ ជាក់ស្ដែង កិច្ចធានារ៉ាប់នេះមិនមែនផ្ដល់ជូនចំពោះតែសាមីជនដែលជាជនរងគ្រោះប៉ុណ្ណោះទេ ច្បាប់ក៏គិតគូ និងជួយសម្រួលបន្ទុកក្រុមគ្រួសារសាមីជនដែលបាត់បង់ប្រភេទចំណូលគ្រួសារមួយផ្នែក ឬទាំងស្រុងដោយសារហានិភ័យការងារ ដូចជាការផ្ដល់ជូននូវផលលាភទៅតាមចំណែកសមាមាត្ររបស់សិទ្ធិវន្តដែលបានកំណត់ក្រោមបទប្បញ្ញត្តិនៃច្បាប់។

ជាក់ស្ដែង ក្នុងការអនុវត្តប្រព័ន្ធធានារ៉ាប់រងរបបសន្តិសុខសង្គម ជាពិសេសផ្នែកហានិភ័យការងារនេះមានការជួបប្រទះនូវឧបសគ្គមួយចំនួន ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ពីសំណាក់ស្ថាប័ន និងបុគ្គលពាក់ព័ន្ធក្នុងការផ្ដល់សេវាធានារ៉ាប់រងជូនសមាជិកប.ស.ស.។ យោងតាមរបាយការណ៍ស្ដីពីលទ្ធផលសម្រេចឆ្នាំ២០២២ និងទិសដៅអនុវត្តបន្តរបស់បេឡាជាតិសន្ដិសុខសង្គម របស់បេឡាជាតិសន្តិសុខសង្គមបានឱ្យបញ្ជាក់អំពីបញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងរបបសន្តិសុខសង្គម ដែលក្នុងនោះរួចមាន ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតមិនទាន់មានភាពទូលំទូលាយ ការយល់ដឹងអំពីអត្ថប្រយោជន៍របបសន្តិសុខសង្គមរបស់សាធារណជននៅមានកម្រិត និងការផ្ដល់សេវាជូនសមាជិកប.ស.ស. នៅមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ក៏នៅមានកម្រិត។ ទន្ទឹមនឹងនេះ ប.ស.ស. ក៏បានដាក់ចេញនូវដំណោះស្រាយ ដើម្បីចម្លើយចតទៅនឹងបញ្ហាប្រឈម និងធានាការអនុវត្តច្បាប់ឱ្យមាន

ប្រសិទ្ធិភាព និងទាន់ពេលវេលា។ បន្ថែមពីនេះ ប.ស.ស.ក៏បានលើកឡើងនូវទិសដៅអនុវត្តបន្ត ដើម្បីពង្រឹង និងពង្រីកការអនុវត្តរបស់ស្ថាប័ន និងរបបសន្តិសុខសង្គមទាំងមូលសម្រាប់អនុវត្តនាឆ្នាំខាងមុខ។

# អនុសាសន៍

# អនុសាសន៍

ដើម្បីធានាដល់ការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមឱ្យមានប្រសិទ្ធិភាព និងទាន់ពេលវេលា នៃការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ប.ស.ស.ត្រូវរៀបចំបង្កើតអធិការសន្តិសុខសង្គម ដើម្បីធ្វើការត្រួតពិនិត្យលើកិច្ចការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ទៅតាមសហគ្រាស គ្រឹះស្ថានដែលចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ហើយបុគ្គលិករបស់ខ្លួនជាបុគ្គលដែលស្ថិតក្រោមច្បាប់ស្តីពីការងារ ដើម្បីធានាការចុះបញ្ជិកាជាមួយប.ស.ស.។ ការធ្វើអធិការកិច្ចនេះ ប.ស.ស. អាចធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋានសម្រាប់ធានាពង្រឹងការចុះបញ្ជីចំពោះសហគ្រាសធុនតូច និងមធ្យមតាមទីជនបទ។ លើសពីនេះ ប.ស.ស. ត្រូវពង្រឹងយន្តការតាមដានការអនុវត្តជាក់លាក់របស់សហគ្រាស គ្រឹះស្ថាន ជាពិសេសការពិន័យចំពោះករណីដែលមិនអនុវត្តកាតព្វកិច្ចក្រោមដែនសមត្ថកិច្ច និងវិសាលភាពនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។ ប.ស.ស. ក៏អាចបង្កើតកម្មវិធី កម្មសិក្សាតាមការស្នើសុំពីសហគ្រាស គ្រឹះស្ថាន ឬ សិក្ខាសាលា ឬ ប្រព័ន្ធផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗទៀតត ដើម្បីបណ្តុះបណ្តាល ផ្សាយអំពីអត្ថប្រយោជន៍ និងលើកទឹកចិត្តការអនុវត្តឱ្យភាពទូលំទូលាយ។

ចំពោះការផ្តល់សេវានៅមូលដ្ឋានសុខាភិបាល ដែលជាដៃគូជាមួយប.ស.ស.វិញ ប.ស.ស. អាចធ្វើការពង្រីកការចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល ដើម្បីធានាថាសេវាសុខាភិបាលនឹងទៅដល់ ឬ សមាជិកនឹងទទួលបានសេវាសុខាភិបាលនៅពេលជួនគ្រោះការងារដែលជាហានិភ័យការងារ។ ប.ស.ស. ក៏ត្រូវពង្រឹងយន្តការតាមដាន វាយតម្លៃ កែសម្រួលកម្រិតគុណភាពរបស់សេវាសុខាភិបាលដែលបានផ្តល់ជូនសមាជិក ជាពិសេសធានាគ្មានការរើសអើងបានកើតមានឡើងចំពោះសមាជិកប.ស.ស. និងដើម្បីធានាទំនុកចិត្ត។ បន្ថែមពីនេះ ប.ស.ស. គួរគប្បីសិក្សាទៅលើតម្លៃសុខាភិបាល មួយទៅពីរលើកក្នុងមួយឆ្នាំ ឬច្រើនជាងនេះតាមការចាំបាច់ ដើម្បីធ្វើការកែសម្រួលការទូទាត់ជូនមូលដ្ឋានសុខាភិបាលទៅបរិបទនៃសេដ្ឋកិច្ច។

ដូចនេះ ដើម្បីធ្វើឱ្យការអនុវត្តរបបសន្តិសុខសង្គមប្រព្រឹត្តទៅកាន់តែប្រសើរឡើង ប.ស.ស. និងស្ថាប័នពាក់ព័ន្ធក្នុងការប្រតិបត្តិច្បាប់ស្តីពីរបបសន្តិសុខសង្គម ដាក់ចេញនូវវិធានការថ្មីដើម្បីឱ្យការយល់របស់សាធារណជនកាន់តែទូលំទូលាយ ស្របពេលជាមួយគ្នានេះប.ស.ស.ក៏គួរពង្រឹងនូវសកម្មភាព ឬវិធានការចាំបាច់ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធិភាព និងនិរន្តភាព។

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្ត

1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ដែលប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
2. ច្បាប់ស្តីពីការងារ, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧
3. ច្បាប់ស្តីពីបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារ, ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២
4. ច្បាប់ស្តីពីរបបសន្តិសុខសង្គម, ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩
5. អនុក្រឹត្យលេខ១៦ អនក្រ.បក ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ ២០០៧
6. ប្រកាសលេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស. ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង ប.ស.ស. សម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ការងារ, ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧
7. ប្រកាសលេខ ១១០ កប/ប្រក ស្តីពីការជូនដំណឹងហានិភ័យការងារ,ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨
8. ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ, ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨
9. ប្រកាសលេខ ៤៤៩ ក.ប/ប្រ.ក.ប.ស.ស. ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ, ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧
10. ប្រកាសលេខ ២៣៨ ក.ប/ប្រ.ក ស្តីពីការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព, ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦
11. ប្រកាសលេខ ២៩៤ ក.ប/ប្រក ស្តីពីការកែសម្រួលនៃប្រកាសលេខ ១០៨ កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ, ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤
12. ប្រកាសលេខ ១៤០ កប/ប្រក ស្តីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ, ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

13.ប្រកាសលេខ ៤៧៧ ក.ប/ប្រ.ក.ប.ស.ស ស្តីពីសេវាស្តារនីតិសម្បទា សម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨

14. ប្រកាសលេខ ៤៨០/១៨ ក.ប/ប្រ.ក.ប.ស.ស ស្តីពីការកែសម្រួលប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ, ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨

15. ប្រកាសលេខ ២៣៣ កប/ប្រក ស្តីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ, ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

16. សេចក្តីជូនដំណឹងលេខ ០៣៥/២៣ ប.ស.ស. ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារស្នាក់ការកណ្តាលបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

17. សេចក្តីជូនដំណឹងស្តីពីលទ្ធផលពិធីប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានប្រចាំឆ្នាំ២០២២ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៣ របស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.)

**ឯកសារជាភាសាខ្មែរ**

1. បេឡាជាតិសន្តិសុខសង្គម, របាយការណ៍ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០២២ និងទិសដៅអនុវត្តបន្តរបស់បេឡាជាតិសន្តិសុខសង្គម។

**គេហទំព័រ**

1. បេឡាជាតិសន្តិសុខសង្គម. (២០១៤) ដកស្រង់ចេញពី: http://www.nssf.gov.kh
2. ហាន់ ស.(២០២៣). *កម្ពុជានឹងសម្រេចបានជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ខាងមុខ.* ដកស្រង់ចេញពី: https://www.information.gov.kh/articles/106424 ថ្ងៃទី០៥ មិថុនា ២០២៣។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## ទម្រង់ឯកសារពាក់ព័ន្ធនឹងនីតិវិធី និងបែបបទនៃចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត និងការបង់ភាគទាន

ឧបសម្ព័ន្ធ១. នៃប្រកាសលេខ: ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងរបបប្រាជាតិសន្តិសុខសង្គម

**ទម្រង់ ១.០១**

# បញ្ជិកាសហគ្រាស គ្រឹះស្ថាន

| **សម្រាប់មន្ត្រី ប.ស.ស.** |
|---|
| **លេខចុះបញ្ជីសហគ្រាស គ្រឹះស្ថាន:** ☐☐☐☐☐☐☐☐ |
| **ហត្ថលេខា:**............................ / / |

**១.** ឈ្មោះសហគ្រាស គ្រឹះស្ថាន:..............................................................

ឈ្មោះជាអក្សរឡាតាំង:..............................................................

**២.** អាសយដ្ឋានទីស្នាក់ការកណ្តាល:អគារ/ផ្ទះលេខ..................ផ្លូវ..................ភូមិ..................ឃុំ/សង្កាត់..................

ស្រុក/ខណ្ឌ/ក្រុង..................រាជធានី/ខេត្ត..................លេខទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐

លេខទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:..................

**៣.** អាសយដ្ឋាននៃកន្លែងធ្វើការងារ:អគារ/ផ្ទះលេខ..................ផ្លូវ..................ភូមិ..................ឃុំ/សង្កាត់..................

ស្រុក/ខណ្ឌ/ក្រុង..................រាជធានី/ខេត្ត..................លេខទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐

លេខទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:..................

(ប្រសិនបើអាសយដ្ឋានកន្លែងធ្វើការដូចគ្នាជាមួយនឹងអាសយដ្ឋានទីស្នាក់ការកណ្តាល ចំណុចលេខ ៣ នេះពុំចាំបាច់ត្រូវបំពេញទេ)

**៤.** លេខបញ្ជីពាណិជ្ជកម្ម: ☐☐☐☐☐☐☐☐☐☐☐☐☐ ប្រភេទសហគ្រាស គ្រឹះស្ថាន: ☐☐☐☐ **(សម្រាប់មន្ត្រី ប.ស.ស.)**

កាលបរិច្ឆេទបើកសហគ្រាស គ្រឹះស្ថាន: ........../........../.......... ចំនួនកម្មករនិយោជិតចុះបញ្ជីដំបូង:..................នាក់/ស្រី..................នាក់

**៥.** ឈ្មោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន:..................ភេទ:..........សញ្ជាតិ:..................

ឈ្មោះជាអក្សរឡាតាំង:..............................................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខ:..............................................................

អាសយដ្ឋានអចិន្ត្រៃយ៍:អគារ/ផ្ទះលេខ..................ផ្លូវ..................ភូមិ..................ឃុំ/សង្កាត់..................

ស្រុក/ខណ្ឌ/ក្រុង..................រាជធានី/ខេត្ត..................លេខទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐

លេខទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:..................

**៦.** ឈ្មោះអ្នកគ្រប់គ្រង ឬអ្នកតំណាងនិយោជក:..................ភេទ:..........សញ្ជាតិ:..................

ឈ្មោះជាអក្សរឡាតាំង:..............................................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខ:..............................................................

អាសយដ្ឋានអចិន្ត្រៃយ៍:អគារ/ផ្ទះលេខ..................ផ្លូវ..................ភូមិ..................ឃុំ/សង្កាត់..................

ស្រុក/ខណ្ឌ/ក្រុង..................រាជធានី/ខេត្ត..................លេខទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐

លេខទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:..................

ខ្ញុំសូមសន្យាថា រាល់ព័ត៌មានដែលផ្តល់ជូនខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន។

..................ថ្ងៃទី..........ខែ..........ឆ្នាំ..........

**ហត្ថលេខា និងត្រានិយោជក**

បោះត្រាក្រុមហ៊ុន/អង្គការ/សមាគម/.........នៅទីនេះ (ត្រាផ្លូវការតែមួយគត់)

ចុះហត្ថលេខានៅទីនេះ (ប៊ិចពណ៌ខៀវតែមួយគត់)

**ឯកសារថតចម្លងភ្ជាប់មកជាមួយ:**

- បញ្ជីពាណិជ្ជកម្ម
- ប័ណ្ណប៉ាតង់
- លិខិតឧបករណ៍គតិយុត្តសមមូល
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់និយោជក និងអ្នកតំណាងនិយោជក
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅរបស់និយោជក

**ទម្រង់ ១.០២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សលាកប័ត្រព័ត៌មានសមាជិក ប.ស.ស.

លេខ៖ .............................

**លេខអត្តសញ្ញាណសមាជិក ប.ស.ស.**

☐☐☐☐☐☐☐ - ☐☐☐☐☐☐☐ - ☐

## ក- ព័ត៌មានផ្ទាល់ខ្លួន

១- គោត្តនាម...................... នាម.................................... ជាអក្សរឡាតាំង..................................................
ភេទ......... សញ្ជាតិ.................... ថ្ងៃខែឆ្នាំកំណើត ....../........../........... អត្តសញ្ញាណប័ណ្ណលេខ.................................

២- ទីកន្លែងកំណើត ផ្ទះលេខ............. ផ្លូវ.................. ភូមិ/ក្រុម........................... ឃុំ/សង្កាត់.......................................
ស្រុក/ខណ្ឌ/ក្រុង.......................................... ខេត្ត/រាជធានី.................................................................................

៣- អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ............. ផ្លូវ................... ភូមិ/ក្រុម.......................... ឃុំ/សង្កាត់...............................
ស្រុក/ខណ្ឌ/ក្រុង............................... ខេត្ត/រាជធានី.................................. លេខទូរស័ព្ទ:.......................................

## ខ- ព័ត៌មានការងារ

៤- សហគ្រាស គ្រឹះស្ថាន........................................................... លេខអត្តសញ្ញាណស.ហ ☐☐☐☐☐☐☐☐

៥- មុខងារ.................................................. ប្រាក់ឈ្នួល........................ កាលបរិច្ឆេទចូលធ្វើការ......../........./.........

## គ- ព័ត៌មានគ្រួសារ

៦- ☐ នៅលីវ ☐ រៀបអាពាហ៍ពិពាហ៍ ☐ មេម៉ាយ/ពោះម៉ាយ

៧- គោត្តនាម-នាម.................................................... សញ្ជាតិ..................... ថ្ងៃខែឆ្នាំកំណើត......../........./.........
មុខរបរសព្វថ្ងៃ...........................................................................................................................................

៨- អំពីកូន...........នាក់

១. គោត្តនាម-នាម ..................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ .......................
២. គោត្តនាម-នាម ..................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ .......................
៣. គោត្តនាម-នាម ..................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ .......................
៤. គោត្តនាម-នាម ..................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ .......................

ខ្ញុំបាទ/នាងខ្ញុំ សូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានបំពេញខាងលើនេះពិតជាត្រឹមត្រូវប្រាកដមែន ។

ធ្វើនៅ............ថ្ងៃទី.........ខែ............ឆ្នាំ២០...

**ស្នាមមេដៃស្ដាំសាមីខ្លួន**

ធ្វើនៅ............ថ្ងៃទី..........ខែ...........ឆ្នាំ២០...

**ហត្ថលេខា និងឈ្មោះមន្ត្រីពិនិត្យ**

**ឯកសារចាំបាច់ត្រូវភ្ជាប់ជាមួយ:**
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- លិខិតឆ្លងដែន
- លិខិតបញ្ជាក់ការងារពីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន

ឧបសម្ព័ន្ធ៣. នៃប្រកាសលេខ: ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងរបបសន្តិសុខសង្គម

**ទម្រង់ ១.០៣**

# របាយការណ៍កម្មករនិយោជិត

១. ឈ្មោះសហគ្រាស គ្រឹះស្ថាន:.................................................................................... ២. លេខអត្តសញ្ញាណសហគ្រាស: | | | | | | | | |

៣. ឈ្មោះសហគ្រាសជាអក្សរឡាតាំង:..........................................................................................................................

| ល.រ | លេខអត្តសញ្ញាណសមាជិក ប.ស.ស. | លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | គោត្តនាម | នាម | ភេទ | ស្ថានភាព | ថ្ងៃខែឆ្នាំកំណើត | សញ្ជាតិ | ប្រាក់ឈ្នួល (រៀល) | ភាគទានផ្នែកហានិភ័យការងារ | ភាគទានផ្នែកថែទាំសុខភាព | ភាគទានផ្នែកប្រាក់សោធន | ភាគទានសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលផ្តល់ជូនខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន។

.....................ថ្ងៃទី...........ខែ............ឆ្នាំ............

**ហត្ថលេខា និងត្រានិយោជក**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................................មានតួនាទីជា.......................................
ធ្វើការនៅសហគ្រាស គ្រឹះស្ថាន.......................................................................................................
ជាអក្សរឡាតាំង...............................................................................................................................
លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន: [ ][ ][ ][ ][ ][ ][ ][ ] ដែលមានអាសយដ្ឋាន: អគារ/ផ្ទះ:
លេខ.........................ផ្លូវលេខ.........................ភូមិ.........................ឃុំ/សង្កាត់...............................
ក្រុង/ស្រុក/ខណ្ឌ.........................ខេត្ត/រាជធានី.........................លេខទូរស័ព្ទលើតុ..........................
លេខទូរស័ព្ទដៃ...............................សារអេឡិចត្រូនិក....................................................។

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយកបេឡាជាតិសន្តិសុខសង្គម**

**កម្មវត្ថុ ៖** ផ្តល់ឈ្មោះអ្នកតំណាងនិយោជកចំនួន ០៣ (បី) នាក់។
**យោង ៖** សេចក្តីជូនដំណឹងលេខ ០០១/១១ ប.ស.ស. ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ របស់បេឡាជាតិសន្តិសុខសង្គម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមផ្តល់ឈ្មោះអ្នកតំណាងនិយោជកចំនួន ០៣ (បី) នាក់ ដើម្បីទំនាក់ទំនងជាមួយបេឡាជាតិសន្តិសុខសង្គម ដែលមានរាយនាមដូចខាងក្រោម ៖

| ល.រ | គោត្តនាម-នាម | តួនាទី | លេខអត្តសញ្ញាណកម្មករនិយោជិត | លេខទូរស័ព្ទទំនាក់ទំនង |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |

ខ្ញុំសូមសន្យាថា រាល់ព័ត៌មានដែលបានផ្តល់ជូនខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន។

..............................ថ្ងៃទី..........ខែ..................ឆ្នាំ២០.......
**ហត្ថលេខា និងត្រានិយោជក**

បោះត្រាក្រុមហ៊ុន/អង្គការ/សហគម/..........នៅទីនេះ (ត្រាផ្លូវការតែមួយគត់)
ចុះហត្ថលេខានៅទីនេះ (ប៊ិចពណ៌ខៀវតែមួយគត់)

**សំគាល់៖** ក្នុងករណីប្តូរឈ្មោះអ្នកតំណាង ឬលេខទូរស័ព្ទត្រូវធ្វើតាមទម្រង់នេះ ដោយគ្រាន់តែកែខ្លឹមសារតាមជាក់ស្តែង។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតបញ្ជាក់ការងារ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................................មានតួនាទីជា.................................................
ធ្វើការនៅក្នុងសហគ្រាស គ្រឹះស្ថាន.................................................................................................
លេខអត្តសញ្ញាណសហគ្រាសក្នុង **ប.ស.ស.** ៖ ☐☐☐☐☐☐☐ - ☐ ដែលមានអាសយដ្ឋានៈ អគារ/
ផ្ទះលេខ..........................ផ្លូវលេខ..........................ភូមិ..........................ឃុំ/សង្កាត់..........................
ក្រុង/ស្រុក/ខណ្ឌ..........................ខេត្ត/រាជធានី..........................លេខទូរសារ (Fax)..........................
លេខទូរស័ព្ទលើតុ (Desk Telephone)..........................លេខទូរស័ព្ទដៃ (Hand Phone)..........................
សារអេឡិចត្រូនិក (E-mail).................................................។

## សូមបញ្ជាក់ថា

- ឈ្មោះ.................................................ភេទ.........សញ្ជាតិ..............ថ្ងៃខែឆ្នាំកំណើត......../......../.........
  កាន់អត្តសញ្ញាណប័ណ្ណលេខ..........................លេខទូរស័ព្ទដៃ (Hand Phone)..........................
- ទីកន្លែងកំណើតៈ អគារ/ផ្ទះលេខ..........................ផ្លូវលេខ..........................ភូមិ..........................
  ឃុំ/សង្កាត់..........................ក្រុង/ស្រុក/ខណ្ឌ..........................ខេត្ត/រាជធានី..........................
- ទីលំនៅបច្ចុប្បន្នៈ អគារ/ផ្ទះលេខ..........................ផ្លូវលេខ..........................ភូមិ..........................
  ឃុំ/សង្កាត់..........................ក្រុង/ស្រុក/ខណ្ឌ..........................ខេត្ត/រាជធានី..........................
- ពិតជាបានបម្រើការងារនៅសហគ្រាស គ្រឹះស្ថានរបស់ខ្ញុំបាទ/នាងខ្ញុំ តាំងពីថ្ងៃទី.........ខែ...........ឆ្នាំ.............
  រហូតដល់បច្ចុប្បន្ន នៅផ្នែក.................................................................ពិតប្រាកដមែន។

ខ្ញុំបាទ/នាងខ្ញុំចេញលិខិតបញ្ជាក់នេះឱ្យសាមីខ្លួនយកទៅប្រើប្រាស់តាមការងារណាដែលអាចប្រើបាន។

..........................ថ្ងៃទី.........ខែ...........ឆ្នាំ២០.........

**ហត្ថលេខា និងត្រានិយោជក**

# ប្លង់ទីតាំងសហគ្រាស គ្រឹះស្ថាន

- ឈ្មោះសហគ្រាស គ្រឹះស្ថាន ៖ ........................................................................................................
- ឈ្មោះជាអក្សរឡាតាំង ៖ ........................................................................................................
- លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន (ចេញដោយ ប.ស.ស.) ៖ ☐☐☐☐☐☐☐☐
- អាសយដ្ឋានសហគ្រាស គ្រឹះស្ថាន (ទីស្នាក់ការកណ្តាល) ៖ អគារ/ផ្ទះលេខ.......................ផ្លូវលេខ.......................
  ភូមិ....................ឃុំ/សង្កាត់.......................ក្រុង/ស្រុក/ខណ្ឌ.......................ខេត្ត/រាជធានី.......................
  លេខទូរស័ព្ទលើតុ (Desk Telephone).......................លេខទូរស័ព្ទដៃ (Hand Phone).......................
  សារអេឡិចត្រូនិក (E-mail)........................................................................................................
- អាសយដ្ឋាននៃកន្លែងធ្វើការងារ (សាខា) ៖ អគារ/ផ្ទះលេខ.......................ផ្លូវលេខ.......................ភូមិ.......................
  ឃុំ/សង្កាត់.......................ក្រុង/ស្រុក/ខណ្ឌ.......................ខេត្ត/រាជធានី.......................
  លេខទូរស័ព្ទលើតុ (Desk Telephone).......................លេខទូរស័ព្ទដៃ (Hand Phone).......................
  សារអេឡិចត្រូនិក (E-mail)........................................................................................................

***<u>កំណត់សំគាល់</u> ៖*** ***- ចំពោះសាខាច្រើនត្រូវគូសប្លង់បង្ហាញទីតាំងគ្រប់ចំនួន ទៅតាមទីតាំងដែលមានជាក់ស្តែង***
***- ក្នុងករណីមានការផ្លាស់ប្តូរអាសយដ្ឋាន ត្រូវគូសប្លង់បង្ហាញទីតាំងឡើងវិញស្របតាមការជាក់ស្តែង ។***

**<u>សូមគូសប្លង់លំអិតនៅខាងក្រោម</u> ៖**

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |

ឧបសម្ព័ន្ធ៤. នៃប្រកាសលេខ: ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ស្ដីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ក្នុងបេឡាជាតិសន្តិសុខសង្គម

**ទម្រង់ ១.០៤**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិសន្តិសុខសង្គម**

**នាយកដ្ឋានបញ្ជិកា និងភាគទាន**

# លិខិតប្រកាសបង់ភាគទានរបបសន្តិសុខសង្គម

| ការិយបរិច្ឆេទសម្រាប់លិខិតប្រកាសនេះ: | |
|---|---|
| ពីថ្ងៃទី ខែ ឆ្នាំ | ដល់ថ្ងៃទី ខែ ឆ្នាំ |

| លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | |

សហគ្រាស/គ្រឹះស្ថាន.......................................................................................................

សកម្មភាពសេដ្ឋកិច្ច.......................................................................................................

អាសយដ្ឋាន អគារ..........ផ្លូវ.............ឃុំ/សង្កាត់..................ស្រុក/ខណ្ឌ/ក្រុង....................ខេត្ត/រាជធានី..................

ប្រអប់សំបុត្រ...........ទូរស័ព្ទ.........................ទូរសារ.........................សារអេឡិចត្រូនិក...........................

| | | |
|---|---|---|
| ភាគទានបង់បង្រ្គប់ចំនួន.................នាក់/ស្រី...........នាក់ សម្រាប់ខែ.............................................. | | |
| ប្រាក់ពិន័យអន្តរការណ៍: ☐ ១. មិនព្រមចុះបញ្ជីសហគ្រាស គ្រឹះស្ថាន | | |
| ☐ ២. មិនព្រមចុះបញ្ជីកម្មករនិយោជិត ចំនួន...............នាក់ | | |
| ☐ ៣. មិនបានបង់ភាគទាន សម្រាប់ខែ............................................ | | |
| ☐ ៤. រាយការណ៍កម្មករនិយោជិតមិនត្រឹមត្រូវ ចំនួន..............នាក់ | | |
| ☐ ៥. ផ្សេងៗ.............................................................................. | | |
| ចំនួនភាគទានសម្រាប់កម្មករនិយោជិតចំនួន...........នាក់/ស្រី..........នាក់ | ភាគទានផ្នែកហានិភ័យការងារ | |
| | ភាគទានផ្នែកថែទាំសុខភាព | |
| | ភាគទានផ្នែកប្រាក់សោធន | |
| | **ភាគទានសរុប** | |

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.....................................................ឋានៈ/តួនាទី...................................................នៃសហគ្រាស គ្រឹះស្ថាន ខាងលើ សូមធានាថាព័ត៌មានដែលបានបំពេញក្នុងលិខិតប្រកាសនេះ និងរបាយការណ៍កម្មករនិយោជិតដែលបានផ្តល់ជូនពិតជាត្រឹមត្រូវ ប្រាកដមែន។ ហត្ថលេខា និងត្រា...................................................................កាលបរិច្ឆេទ : ............../............../..............

**សម្រាប់មន្ត្រី ប.ស.ស.**

លេខទទួល..................................................................

កាលបរិច្ឆេទ............/....................../...............

បង់នៅធនាគារ.............................................................

ប្រកាសឥណទានលេខ:...................................................

ចុះថ្ងៃទី................ខែ..................ឆ្នាំ................

ឈ្មោះមន្ត្រី................................ហត្ថលេខា..............

បេឡាជាតិសន្តិសុខសង្គម

(ក្បាលលិខិតរបស់សហគ្រាស)
Letter Head Company

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................................មានតួនាទីជា...............................................
ធ្វើការនៅក្នុងសហគ្រាសយីហោ.................................................................................................................
លេខអត្តសញ្ញាណសហគ្រាស | | | | | | | | | អាសយដ្ឋានអគារលេខ...............
ផ្លូវលេខ.......................ភូមិ................ឃុំ/សង្កាត់............................ក្រុង/ស្រុក/ខណ្ឌ...............................
ខេត្ត/រាជធានី....................................លេខទូរស័ព្ទលើតុ (Desk Telephone)................................................
លេខទូរស័ព្ទដៃ (Hand Phone)..................................................លេខទូរសារ (Fax)....................................
សារអេឡិចត្រូនិច (E-mail)........................................................................................... ។

**<u>សូមគោរពជូន</u>**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម**

**<u>កម្មវត្ថុ</u>** ៖ របាយការណ៍អំពីចំនួនកម្មករនិយោជិតប្រចាំខែ....................ឆ្នាំ២០........... ។

**<u>យោង</u>** ៖- ប្រកាសលេខ ៤៤៩ ក.ប./ប្រ.ក.ប.ស.ស. ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

- ប្រកាសអន្តរក្រសួងលេខ ៤០៤ ក.ប./ប្រ.ក.ប.ស.ស. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** មេត្តាជ្រាបថា កម្មករនិយោជិតដែលសហគ្រាស គ្រឹះស្ថានបានប្រើប្រាស់មានចំនួន........................នាក់ ស្ត្រីចំនួន..................នាក់ និងកម្មករនិយោជិតជាស្ត្រីដែលកំពុងមានគភ៌មានចំនួន.....................នាក់ ដូចមាននៅក្នុងរបាយការណ៍ដែលបានថតចម្លងជូនភ្ជាប់មកជាមួយក្នុងថាស CD ឬ USB Flash ។

ខ្ញុំសូមសន្យាថា រាល់ព័ត៌មានដែលខ្ញុំបាទ/នាងខ្ញុំបានផ្តល់ជូន ពិតជាត្រឹមត្រូវប្រាកដមែន ។

ថ្ងៃ...............................ខែ........................ឆ្នាំ.............................ព.ស.២៥.....

.........................ថ្ងៃទី...........ខែ................ឆ្នាំ២០.....

**ហត្ថលេខា និងត្រានិយោជក**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..........................................................មានតួនាទីជា..................................................
ធ្វើការនៅក្នុងសហគ្រាស គ្រឹះស្ថាន..........................................................................................................................
លេខអត្តសញ្ញាណសហគ្រាសក្នុង **ប.ស.ស.** ៖ ☐☐☐☐☐☐☐ - ☐ ដែលមានអាសយដ្ឋានៈ អគារ/
ផ្ទះលេខ.............................ផ្លូវលេខ.................................ភូមិ.................................ឃុំ/សង្កាត់...................................
ក្រុង/ស្រុក/ខណ្ឌ....................................ខេត្ត/រាជធានី.......................................លេខទូរសារ (Fax)....................................
លេខទូរស័ព្ទលើតុ (Desk Telephone)........................................លេខទូរស័ព្ទដៃ (Hand Phone)......................................
សារអេឡិចត្រូនិក (E-mail)...........................................................................។

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយកបេឡាជាតិសន្តិសុខសង្គម**

**កម្មវត្ថុ** ៖ សំណើសុំទុតិយតាវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថានឡើងវិញ។
**មូលហេតុ** ៖ ....................................................................................................................................................
....................................................................................................................................................................។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** មេត្តាអនុញ្ញាត ចេញទុតិយតាវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថានរបស់ខ្ញុំបាទ/នាងខ្ញុំឡើងវិញ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ...............................ខែ......................ឆ្នាំ...........................ព.ស.២៥.........
.......................... ថ្ងៃទី..........ខែ..............ឆ្នាំ២០.........
**ហត្ថលេខា និងត្រានិយោជក**

បោះត្រាក្រុមហ៊ុន/អង្គការ/ សមាគម/.........នៅទីនេះ (ត្រាផ្លូវការតែមួយគត់)

ចុះហត្ថលេខានៅទីនេះ (ប៊ិចពណ៌ខៀវតែមួយគត់)

